Empowered lives.
Resilient nations.

# ការបន្សុាំកិច្ចគាំពារសង្គមនៅប្រទេសកម្ពុជា

## ឯកសារយុទ្ធសាស្ត្រ



ឆ្នាំ ២០១៥

ទស្សនៈដែលមាននៅក្នុងឯកសារនេះ គឺជាទស្សនៈរបស់អ្នករៀបរៀង និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់កម្មវិធីអភិវឌ្ឍន៍
សហប្រជាជាតិទេ។

***Photo Credit:*** *(Left to Right)*

- Water flows down from an irrigation system in Anglong Veng, Oddar Meanchey province. (UNDP, Chansok Lay)
- A girl collects snails for sale in Oddar Meanchey province (UNDP, Chansok Lay)
- Cambodian farmers pluck rice seedling for replanting in a rice field in Oddar Meanchey province. (UNDP, Chansok Lay)

# មាតិកា


១. សេចក្តីផ្តើម និងព័ត៌មានមូលដ្ឋាននៃរបាយការណ៍ ........ 5

២. ពិនិត្យឡើងវិញនូវលទ្ធផលនៃការវិភាគពីស្ថានភាព ........ 6

២.១. បម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយនៅកម្ពុជា ........ 6

២.២. ស្ថានភាពទូទៅនៃកិច្ចគាំពារសង្គមនៅកម្ពុជា ........ 7

២.៣. ការរកឃើញ ........ 7

២.៣.១. សមត្ថភាពបន្សាំការប្រែប្រួលអាកាសធាតុរបស់ប្រទេសកម្ពុជា ........ 7

២.៣.២. បរិធានកាត់បន្ថយគ្រោះមហន្តរាយ ........ 8

២.៣.៣. ទិដ្ឋភាពគោលនយោបាយ និងការអនុវត្តកិច្ចគាំពារសង្គម ........ 8

២.៣.៤. ការបន្សាំកិច្ចគាំពារសង្គម (ការធ្វើសមាហរណកម្មរវាងកិច្ចគាំពារសង្គម ការបន្សាំការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយ) ........ 9

៣. សង្ខេបលទ្ធផលសិក្ខាសាលាស្តីពីទ្រឹស្តីនៃការផ្លាស់ប្តូរ ........ 9

៣.១ បញ្ហាសំខាន់ៗ ........ 9

៣.១.១. សិក្ខាសាលាពិគ្រោះយោបល់ជាមួយបុគ្គលិកអង្គការ UNDP ........ 10

៣.១.២. សិក្ខាសាលាពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធខាងក្រៅ (រួមទាំងមន្ត្រីរដ្ឋាភិបាល) ........ 10

៤. ផែនទីបង្ហាញផ្លូវសម្រាប់របៀបវារៈការបន្សាំកិច្ចគាំពារសង្គមនៅកម្ពុជា ........ 11

៤.១. គោលការណ៍សំខាន់ៗ ........ 11

៤.២. បញ្ញត្តិណែនាំ ........ 12

៤.៣. ការសន្មត់នានា ........ 12

៤.៤. ផែនទីបង្ហាញផ្លូវ ........ 13

៤.៤.១ ដំណាក់កាលដំបូង (៦ខែ) ........ 14

៤.៤.២ ដំណាក់កាលទី១ (១ឆ្នាំ) ........ 15

៤.៤.៣ ដំណាក់កាលទី២ (១ឆ្នាំ) ........ 16

៤.៤.៤ ដំណាក់កាលទី៣ (២ឆ្នាំ) ........ 17

៤.៤.៥ ដំណាក់កាលទី៤ (១ឆ្នាំ) ........ 18

៥. ឯកសារពិគ្រោះ ........ 19

# បញ្ជីអក្សរកាត់

| | |
|---|---|
| ASP | ការបន្សាំកិច្ចគាំពារសង្គម |
| CARD | ក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| CCA | ការបន្សាំការប្រែប្រួលអាកាសធាតុ |
| CCCA | សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុនៅកម្ពុជា |
| CCCSP | ផែនការយុទ្ធសាស្រ្តបំរែបំរួលអាកាសធាតុសម្រាប់ប្រទេសកម្ពុជា |
| CCDM | គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយឃុំ |
| DCDM | គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយស្រុក |
| DRR | ការកាត់បន្ថយគ្រោះមហន្តរាយ |
| IDS | វិទ្យាស្ថានសិក្សាការអភិវឌ្ឍន៍ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoE | ក្រសួងបរិស្ថាន |
| MoP | ក្រសួងផែនការ |
| M&E | ត្រួតពិនិត្យ និងវាយតម្លៃ |
| NAPA | កម្មវិធីសកម្មភាពជាតិលើការបន្សាំការប្រែប្រួលអាកាសធាតុ |
| NCCC | គណៈកម្មការជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| NCDM | គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NCRP | ផែនការជាតិឆ្លើយតបនឹងយថាភាព |
| NSDP | ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ |
| NSPS | យុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ |
| PCDM | គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RSPIII | យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ |
| SNAP | ផែនការយុទ្ធសាស្រ្តសកម្មភាពជាតិ |
| SP | កិច្ចគាំពារសង្គម |
| UNDP-CO | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ការិយាល័យប្រចាំប្រទេសកម្ពុជា |
| UNFCCC | អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការបំរែបំរួលអាកាសធាតុ |
| NCDD | គណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# សេចក្តីថ្លែងអំណរគុណ

ឯកសាយុទ្ធសាស្ត្រមួយនេះត្រូវបានបោះពុម្ពផ្សាយដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងរៀបរៀងដោយ លោក គ្រីស បេណេ នៃវិទ្យាស្ថានសិក្សាកិច្ចការអភិវឌ្ឍន៍ និងលោក ប្រ៊ែត អ៊ែម បាឡេដ។ សេចក្តីបរិយាយ និងឯសារសារតាប្រើប្រាស់ជាធាតុចូលសំរាប់របាយការណ៍ ត្រូវបាន សំរបសំរួល និងគាំទ្របច្ចេកទេសដោយអ្នកស្រី ម៉ារីសា ហ្វូរាស៊ី សេដ្ឋវិទូ និងលោកហង់ សុវណ្ណារិទ្ធ អ្នកសំរបសំរួលគំរោង របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា។

សូមស្ញើចសរសើរដល់ផ្នែកទទួលបន្ទុកកិច្ចគាំពារសង្គម នៃក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ នាយកដ្ឋានបំរែបរួលអាកាសធាតុនៃក្រសួងបរិស្ថាន និងគណៈកម្មាធិការជាតិគ្រប់គ្រង គ្រោះមហន្តរាយ ចំពោះកិច្ចសហការ និងការគាំទ្រនៅកំឡុងពេលធ្វើការវិភាគស្ថានភាព និងចំពោះ ការពិនិត្យកែតំរូវទៅលើ អនុសាសន៍គោលនយោបាយ នៃឯកសារយុទ្ធសាស្ត្រនេះ។

ការរៀបរៀងរបាយការណ៍នេះត្រូវបានដឹកនាំ តាមរយៈការអានឡើងវិញដោយប្រុងប្រយ័ត្ន នូវការវិភាគ ការបន្សាំកិច្ចគាំពារសង្គមដែលនិពន្ធរួមគ្នាដោយ លោកជ័យ តិច និងលោក គ្រីស បេណេ និងចូលរួមអោយ សំរេចឡើងបាន តាមរយៈសិក្ខាសាលាពីរ ដែលដឹកនាំដោយ លោកស្រី យូមីកុ យ៉ាម៉ាម៉ូតុ អ្នកឯកទេសផ្នែកគោលនយោបាយ រួមជាមួយអ្នកស្រី ចូអាន ម៉ាន់ដា អ្នកឯកទេសហិរញ្ញវត្ថុការបំរែបំរួលអាកាសធាតុ នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិការិយាល័យប្រចាំតំបន់ អាស៊ីប៉ាស៊ីហ្វិច។

នៅគ្រប់ដំណើរការទាំងអស់ដែលឈានទៅដល់ការបញ្ចប់ទាំងស្រុងនៃរបាយការណ៍ យើងខ្ញុំបានទទួល ការពន្យល់ និងណែនាំដ៏មានតំលៃមិនអាចកាត់ថ្លៃបានពីសំណាក់ លោក ណាប៉ូឡេអុង ណាវ៉ារ៉ូ នាយករង និងក្រុមការងារផ្នែកថាមពលនិងបរិស្ថាននៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា។

សូមថ្លែងអំណរអរគុណជាពិសេសជូន ឯកឧត្តម ទិន ពន្លក អគ្គនាយករងទទួលបន្ទុកការបំរែបំរួលអាកាសធាតុ និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍បៃតង  ឯកឧត្តម សាន វឌ្ឍនា អគ្គលេខាធិការរង ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍវិស័យកសិកម្មនិងជនបទ និងឯកឧត្តម រស់ សុវណ្ណ អគ្គលេខាធិការរង គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ ចំពោះការផ្តល់ធាតុចូលជាយុទ្ធសាស្ត្រតាមរយៈការចូលរួមនៅក្នុងដំណើរការ ពិគ្រោះយោបល់ ។

# ១. សេចក្តីផ្តើម និងព័ត៌មានមូលដ្ឋាននៃរបាយការណ៍

កិច្ចគាំពារសង្គម ការកាត់បន្ថយគ្រោះមហន្តរាយ និងការបន្សាំការប្រែប្រួលអាកាសធាតុ គឺជាស្ថាប័នអនុវត្តន៍ចំនួនបីដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងចំបង ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិ និងគ្រោះថ្នាក់ចំពោះបុគ្គល និងសហគមន៍។ រហូតមកដល់បច្ចុប្បន្ននេះ បើទោះជាវិស័យទាំងបីនេះហាក់បីដូចជាមិនទាន់បានទទួលស្គាល់ពីចំណុចរួមគ្នា និងរបៀបវារៈដូចគ្នា ព្រមទាំងមិនអាចដោះស្រាយនូវឧបសគ្គរវាងស្ថាប័ន ហើយទំនាក់ទំនងគ្នានៅមានភាពទន់ខ្សោយនៅឡើយ។ ទាំងអស់នេះ គឺជាការលំបាកដែលកំពុងតែកើតមាននៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅបណ្តាប្រទេសជាច្រើនទៀត។

អ្នកជំនាញ និងអ្នកអនុវត្តជាច្រើននៅមិនទាន់ទទួលស្គាល់ថាការធ្វើសមាហរណកម្មកិច្ចគាំពារសង្គម ការកាត់បន្ថយគ្រោះមហន្តរាយ និងការបន្សាំការប្រែប្រួលអាកាសធាតុនេះនឹងជួយបង្កើត និងជំរុញកាន់តែខ្លាំងលើកិច្ចអន្តរាគមន៍កាត់បន្ថយភាពងាយរងគ្រោះ។ នៅកន្លែងដែលជួបនូវកង្វះខាតទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ វិធីសាស្រ្តសមាហរណកម្ម ឬសម្របសម្រួលនឹងអាចជួយកាត់បន្ថយហានិភ័យភាពត្រួតគ្នា ឬប៉ះទង្គិចគ្នារវាងកិច្ចអន្តរាគមន៍ របស់វិស័យទាំងបីនេះ។

នៅក្នុងបរិបទនេះ តាមរយៈការបោះផ្សាយនូវរបាយការណ៍អភិវឌ្ឍន៍មនុស្សថ្នាក់ជាតិស្តីពី "អនាគតនៃការចិញ្ចឹមជីវិតនៅជនបទក្នុងការប្រឈមមុខនឹង ការផ្លាស់ប្តូរអាកាសធាតុនៅឆ្នាំ 2011 ដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ការិយាល័យប្រចាំប្រទេសកម្ពុជា (UNDP-CO) បានសម្រេចពិចារណាពីលទ្ធភាព នៃការការពង្រឹងការធ្វើសមាហរណកម្មរវាងកិច្ចគាំពារសង្គម (Social Protection-SP) ការបន្សាំនិងបំរែបំរួលអាកាសធាតុ (Climate Change Adaptation-CCA) និងការកាត់បន្ថយគ្រោះមហន្តរាយ (Disaster Risk Reduction-DRR) នៅក្នុងកម្មវិធី និងគម្រោងរបស់ពួកគេតាមរយៈសេចក្តីណែនាំនូវទស្សនាទានបន្សាំកិច្ចគាំពារសង្គម (Adaptive Social Protection-ASP)។ ទស្សនាទានការបន្សាំ កិច្ចគាំពារសង្គម (ASP) ត្រូវបានគេទទួលស្គាល់ថាជាក្របខ័ណ្ឌមួយដ៏មានសារៈសំខាន់ ក្នុងការជម្រុញការធ្វើសមាហរណកម្ម កិច្ចគាំពារសង្គម ការបន្សាំការផ្លាស់ប្តូរអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងការអនុវត្តន៍ (Davies et al ឆ្នាំ 2008, Davies et al 2009)។ ការដាក់បញ្ចូលនូវវិស័យទាំងបីអោយធ្វើការងាររួមគ្នាក្នុងគោលបំណង ដើម្បីបង្កើតនូវក្របខ័ណ្ឌមួយដែលជួយដល់កិច្ចអន្តរាគមន៍ ការគាំពារសង្គមកាន់តែធន់ថែមទៀត ចំពោះហានិភ័យពីគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ព្រមជាមួយការជំរុញការយល់ដឹងថាតើកិច្ចគាំពារសង្គម តាមរយៈកិច្ចកាត់បន្ថយភាពងាយរងគ្រោះអាចដើរតួនាទីសំខាន់យ៉ាងដូចម្តេច នៅក្នុងការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានពីបំរែបំរួលអាកាសធាតុ និងគ្រោះមហន្តរាយ។ ជាគោលគំនិតរបស់ការបន្សាំកិច្ចគាំពារសង្គមគឺ មានបំណងប្រឹងប្រែងដោយផ្ទាល់ដើម្បីឆ្លើយតបចំពោះរបាំង កិច្ចអន្តរាគមន៍រវាងកិច្ចគាំពារសង្គមការបន្សាំនឹងបំរែបំរួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយ ដែលជានិច្ចជាកាលតែងតែរាំងអ្នកកសាងគោលនយោបាយ ស្ថាប័ន និងអនុវត្តទាំងឡាយទាំងបីនេះក្នុងការធ្វើការរួមគ្នា។

របាយការណ៍មួយនេះ គឺជាសមាសភាគទីបីនៃការផ្តួចផ្តើមរបស់កម្មវិធីអភិវឌ្ឍសហប្រជាជាតិប្រចាំកម្ពុជា (UNDP-CO) ទាក់ទងនឹងការបន្សាំកិច្ចគាំពារសង្គម ដែលបានរៀបរាប់ខាងលើ។ ការសិក្សាវិភាគស្ថានភាពស្តីពីការបន្សាំកិច្ចគាំពារសង្គមនៅកម្ពុជា (Béné and Tech 2014) និងសិក្ខាសាលាចំនួនពីរស្តីពីទ្រឹស្តីនៃការផ្លាស់ប្តូរ (Manda and Yamamoto 2014) ដែលបានរៀបចំនិងសម្របសម្រួលដោយ UNDP-CO ស្របពេលជាមួយគ្នា និងការរៀបចំឯកសារយុទ្ធសាស្រ្តនេះដែរ។ ទាំងការវិភាគស្ថានភាព និងសិក្ខាសាលាស្តីពីទ្រឹស្តីនៃការផ្លាស់ប្តូរមានបំណងប្រមូលនូវព័ត៌មានសំខាន់ៗ សម្រាប់ការរៀបចំឯកសារយុទ្ធសាស្រ្តស្តីពីការបន្សាំកិច្ចគាំពារសង្គមមួយនេះ។

ឯកសារយុទ្ធសាស្ត្រនេះ បង្ហាញពីក្របខ័ណ្ឌមួយ (ផែនទីបង្ហាញផ្លូវមួយ) នៅជុំវិញវិស័យទាំងបី កំពុងអនុវត្តនៅប្រទេសកម្ពុជា អាចនឹងរកឃើញនូវឱកាសសហការ ក្នុងការរៀបចំគម្រោងការអនុវត្តន៍ ការត្រួតពិនិត្យ និងវាយតម្លៃលើអន្តរាគមន៍កម្មវិធី ASP។ ឯកសារយុទ្ធសាស្ត្រនេះ ដាក់ចេញនូវការអនុវត្តន៍មួយដែលមានរយៈ 10ឆ្នាំ ដោយផ្តោតជាសំខាន់ទៅលើសកម្មភាពជាច្រើនក្នុងរយៈពេល 5ឆ្នាំដំបូង។ សកម្មភាពទាំងនោះរួមមាន ការបញ្ជ្រាបការយល់ដឹង ការកំណត់ចំណុចចាប់ផ្តើមការកសាងសមត្ថភាព ការរៀនសូត្រតាមរយៈការអនុវត្តន៍ និងការបង្កើតភាពជាដៃគូដ៏មានប្រសិទ្ធិភាព ជាមួយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា។

# ២. ពិនិត្យឡើងវិញនូវលទ្ធផលនៃការវិភាគពីស្ថានភាព

ឯកសារលំអិតពេញលេញនៃការវិភាគស្ថានភាពស្តីពីការបន្សាំកិច្ចគាំពារសង្គមកម្ពុជា ដែលរៀបចំឡើងដោយលោក Béné and Tech (2014) មានភ្ជាប់នៅឧបសម្ព័ន្ធទី 1។ ខាងក្រោមនេះ គឺជាការសង្ខេបនូវលទ្ធផលសំខាន់ៗនៃរបាយការណ៍។

## ២.១. បម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយនៅកម្ពុជា

ប្រទេសកម្ពុជាត្រូវបានចាត់ ទុកជាប្រទេសងាយរងគ្រោះបំផុតទីពីរនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ពោលគឺបន្ទាប់ពីប្រទេសបង់ក្លាដេស។ ទឹកជំនន់ និងគ្រោះរាំងស្ងួត គឺមានផលប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ច និងសង្គម ជាពិសេសសម្រាប់គ្រួសារនៅជនបទក្នុងប្រទេសកម្ពុជា(បើប្រៀបធៀបផលប៉ះពាល់គ្រោះមហន្តរាយ ដែលបានកើតមាននៅបណ្តាប្រទេសផ្សេងៗនៅក្នុងតំបន់ មានដូចជាប្រទេសបង់ក្លាដែសជាដើម) មិនមែនដោយសារតែភាពធ្ងន់ធ្ងរនៃព្រឹត្តិការណ៍នោះទេ ប៉ុន្តែដោយសារតែគ្រួសារនៅជនបទក្នុងប្រទេសកម្ពុជា មិនបានត្រៀមខ្លួនក្នុងការឆ្លើយតបចំពោះការកើតមាននូវគ្រោះមហន្តរាយ មកលើខ្លួនឡើយ ក៏ព្រោះតែកង្វះសមត្ថភាពរបស់ប្រជាជនកម្ពុជាក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយដែលកើតមានទាំងនោះ។ ការផ្លាស់ប្តូរអាកាសធាតុនឹងបង្កើនជាបញ្ហាកាន់តែធ្ងន់ធ្ងរបន្ថែមទៀតដល់ពួកគាត់។

ការគំរាមកំហែង និងភាពជាក់ស្តែងដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ត្រូវបានទទួលស្គាល់កាន់តែខ្លាំងឡើងពីសំណាក់រដ្ឋាភិបាលកម្ពុជា តាមរយៈការអនុម័តគោលនយោបាយជាច្រើន ដែលពាក់ព័ន្ធទៅនឹងការបន្សាំបម្រែបម្រួលអាកាសធាតុ។ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពី ការបំរែបំរួលអាកាសធាតុក្នុងឆ្នាំ 1995 និងចូលជាសមាជិកពិធីសារក្យូតូក្នុងឆ្នាំ 2002។ នៅឆ្នាំ 2006 ប្រទេសកម្ពុជាបានដាក់ចេញនូវកម្មវិធីសកម្មភាពជាតិលើការបន្សាំការប្រែប្រួលអាកាសធាតុ (NAPA) របស់ខ្លួន ព្រមទាំងដាក់ចេញនូវគម្រោងអាទិភាពមួយក្នុងការដោះស្រាយជាចាំបាច់ក្នុងការបន្សាំ ការផ្លាស់ប្តូរអាកាសធាតុ។ គម្រោងទាំងនេះ សមស្របទៅនឹងគោលបំណងអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ដូចមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ នៅក្នុងឆ្នាំ 2004 សម្រាប់កំណើនសេដ្ឋកិច្ច ការងារ សមធម៌ និងប្រសិទ្ធិភាព ក៏ដូចជានៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ2006-2010 ។

ក្រោយពីការដាក់ចេញនូវ NAPA ក៏មានឯកសារគន្លឹះមួយចំនួនផ្សេងទៀត ព្រមទាំងការផ្តួចផ្តើមមួយចំនួនទៀតត្រូវបានរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដែលមានទំនាក់ទំនងយ៉ាងខ្លាំងទៅនិងការបន្សាំការផ្លាស់ប្តូរអាកាសធាតុ។ ជាពិសេស គណៈកម្មាធិការជាតិ គ្រប់គ្រងការប្រែប្រួលអាកាសធាតុ(NCCC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2006 ដើម្បីដើរតួនាទីសម្របសម្រួល និងត្រួតពិនិត្យការអនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្របទបញ្ញត្តិ ផែនការ និងកម្មវិធីនានាក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ។ នៅក្នុងឆ្នាំ 2011 ផែនការយុទ្ធសាស្ត្រស្តីពីការផ្លាស់ប្តូរអាកាសធាតុកម្ពុជា (CCCSP) ត្រូវបានបង្កើតឡើងរួមជាមួយនឹងយុទ្ធសាស្ត្រ និងផែនការសកម្មភាពតាមវិស័យ។

ស្របពេលជាមួយគ្នាដែរ ការបញ្ជ្រាបការបង្ការគ្រោះមហន្តរាយនៅតាមក្រសួងពាក់ព័ន្ធត្រូវបានដាក់បញ្ចូលក្នុងឯកសារសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលរួមទាំងផែនការសកម្មភាពយុទ្ធសាស្ត្រជាតិស្តីពី ការកាត់បន្ថយគ្រោះមហន្តរាយឆ្នាំ2008 - 2015 (SNAP) ផែនការជាតិឆ្លើយតបជាយថាភាព (NCRP)

ដើម្បីឆ្លើយតបគ្រោះមហន្តរាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី III ឆ្នាំ2014-2018។ ក្នុងចំណោមបញ្ហាអន្តរវិស័យដែលផែនការទាំងនេះ ព្យាយាមសម្រេចបានផងដែរ គឺរួមមានបញ្ហាយេនឌ័រ បរិស្ថាន ធនធានធម្មជាតិ និង ការអភិវឌ្ឍន៍បៃតង ការគ្រប់គ្រងគ្រោះមហន្តរាយ និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

ក្រៅពីសកម្មភាពនៅកម្រិតជាតិ ការពង្រឹងសមត្ថភាពថ្នាក់ក្រោមជាតិត្រូវបានយកចិត្តទុកដាក់ ជាពិសេសកម្រិតសហគមន៍ក្នុងការគាំទ្រយ៉ាងពេញទំហឹង ដល់អាទិភាពរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ដូចមានចែងនៅក្នុងផែនការអភិវឌ្ឍន៍ជាតិ និងគោលនយោបាយនានា។

## ២.២. ស្ថានភាពទូទៅនៃកិច្ចគាំពារសង្គមនៅកម្ពុជា

តាមរយៈការអនុម័តផែនការមេសម្រាប់ការបង្កើតជាទាវ៉ាប់រងសុខភាពសង្គមនៅឆ្នាំ 2003 ប្រទេសកម្ពុជាបានបោះជំហានដំបូងឆ្ពោះទៅរកប្រព័ន្ធគាំពារសុខភាពសង្គមរួមមួយ។ ចាប់តាំងពីពេលនោះមក គោលនយោបាយ និងគោលការណ៍ណែនាំជាតិមួយចំនួនត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យការពង្រីកនូវយន្តការកិច្ចគាំពារសុខភាពសង្គម ដែលមានគោលដៅចុងក្រោយនូវការគ្របដណ្តប់ជាទូទៅ។

នៅឆ្នាំ 2009 រាជរដ្ឋាភិបាលកម្ពុជា បានតែងតាំងក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) ដើម្បីគាំទ្រ ក្រុមការងារបណ្តោះអាសន្នស្តីពីបណ្តាញសុវត្ថិភាពសង្គម (IWG-SSN) ក្នុងការរៀបចំសមាហរណកម្មយុទ្ធសាស្ត្រជាតិគាំពារសង្គម (NSPS) ។ NSPS នេះ ត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីហើយបន្ទាប់មកបានបើកសម្ពោធដាក់អោយអនុវត្តនៅខែធ្នូ ឆ្នាំ 2011 ។

នាពេលបច្ចុប្បន្ននេះ កិច្ចគាំពារសង្គមត្រូវបានផ្តល់ជូនដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងពាក់ព័ន្ធនានា ក៏ដូចជាតាមរយៈកម្មវិធីគាំទ្រដោយម្ចាស់ជំនួយផងដែរ។ ជារួមកម្មវិធីគាំពារសង្គមទាំងនេះ ត្រូវបានចំណាយប្រមាណ 5,5 ភាគរយនៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាក្នុងឆ្នាំ 2010 (អង្គការពលកម្មអន្តរជាតិឆ្នាំ 2012)។ បើយោងតាមប្រព័ន្ធទិន្នន័យសន្តិសុខសង្គម របស់អង្គការពលកម្មអន្តរជាតិឃើញថាការចំណាយសាធារណៈ លើកិច្ចគាំពារសង្គមមានចំនួនត្រឹមតែ 1,79 ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ 2011 (អង្គការពលកម្មអន្តរជាតិឆ្នាំ2012) ហើយការចំណាយដែលនៅសល់គឺបានមកពីការគាំទ្ររបស់ម្ចាស់ជំនួយ។

## ២.៣. ការរកឃើញ

ផ្អែកលើព័ត៌មាន និងទិន្នន័យដែលបានប្រមូលក្នុងអំឡុងពេលសិក្សាវិភាគស្ថានភាពការបន្សាំកិច្ចគាំពារសង្គម គឺអាចឈានទៅដល់ការចេញនូវសេចក្តីសន្និដ្ឋានមួយចំនួនទាក់ទងទៅនឹងកិច្ចគាំពារសង្គម ការកាត់បន្ថយគ្រោះមហន្តរាយ និងការបន្សាំការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

### ២.៣.១. សមត្ថភាពបន្សាំការប្រែប្រួលអាកាសធាតុរបស់ប្រទេសកម្ពុជា

យោងតាមឯកសារវាយតម្លៃមួយចំនួនលើការបន្សាំការប្រែប្រួលអាកាសធាតុ បានលើកឡើងនូវសំណួរដែលទាក់ទងនឹងសមត្ថភាពស្ថាប័ន និងបុគ្គលគឺនៅមានកំរិត គឺរួមទាំងក្នុងស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។ ការសន្និដ្ឋានស្រដៀងគ្នាមួយក៏ត្រូវបានលើកឡើងដែរ ក្នុងអំឡុងពេលសម្ភាសន៍ប្រមូលព័ត៌មានជាមួយបុគ្គលសំខាន់ៗ (Key Informants) និងតាមរយៈ ឯកសារជាច្រើនរបស់រាជរដ្ឋាភិបាលកម្ពុជា។ យុទ្ធសាស្ត្រជាតិគាំពារសង្គម 2011-2015 បានចង្អុលបង្ហាញថា "ទោះបីជាតំបន់ជាច្រើននៅក្នុងប្រទេសកម្ពុជាត្រូវបានការពារពីគ្រោះថ្នាក់អាកាសធាតុ ប៉ុន្តែស្ទើរតែគ្រប់តំបន់គឺចាត់ទុកថាមានភាពងាយរងគ្រោះពីផលប៉ះពាល់ នៃការផ្លាស់ប្តូរអាកាសធាតុ ដោយហេតុមកពីសមត្ថភាពបន្សាំនៅមានកម្រិតទាប ជាលទ្ធផលនៃកង្វះហិរញ្ញវត្ថុ បច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ និងឧបសគ្គទំនាក់ទំនងស្ថាប័ន" (RGC 2011: 22,) ។

ក្រៅពីកម្រិតជាតិ កត្តាមួយទៀតដែលបានរកឃើញនោះគឺថាសមត្ថភាពរបស់រដ្ឋបាល និងប្រជាជនថ្នាក់មូលដ្ឋាននៅមានកំរិតទាបនៅឡើយ ដែលទាមទារឱ្យមានការពង្រឹងសមត្ថភាពជាចាំបាច់។

## ២.៣.២. បរិធានកាត់បន្ថយគ្រោះមហន្តរាយ

តាមរយៈការពិនិត្យនូវឯកសារដែលមានស្រាប់ បានបង្ហាញថា ការកាត់បន្ថយគ្រោះមហន្តរាយ គឺជារបៀបវារៈដ៏សំខាន់បំផុត ប៉ុន្តែកង្វះនូវសមត្ថភាព និងធនធានទាក់ទងទៅនឹងការកាត់បន្ថយគ្រោះមហន្តរាយ នៅតែជាឧបសគ្គដល់វឌ្ឍនភាពក្នុងវិស័យនេះ។ ឯកសារមួយចំនួនបានទទួលស្គាល់ ជាពិសេសក្នុងចំណោមមូលហេតុជាច្រើន គឺបញ្ហាការសម្របសម្រួលស្ថាប័នថ្នាក់ជាតិ ដែលទទួលបន្ទុកគ្រប់គ្រងគ្រោះមហន្តរាយ (គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ) មិនបានទទួលការគាំទ្រគ្រប់គ្រាន់ពីរដ្ឋាភិបាលថ្នាក់ជាតិ ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធិភាពទៅតាមអាណត្តិរបស់ខ្លួន ។ ក្នុងការដោះស្រាយបញ្ហាទាំងនេះ គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានកំពុងខិតខំប្រឹងប្រែងជំរុញអោយមានការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយអោយបានឆាប់ដើម្បីដោះស្រាយបញ្ហាកង្វះធនធាន។ នៅថ្នាក់ក្រោមជាតិ ឬថ្នាក់ខេត្ត បញ្ហាហាក់បីដូចជាលំបាកជាងនេះទៅទៀតចំពោះកង្វះធនធាន ដើម្បីដាក់បញ្ចូលផែនការអនុវត្តគោលនយោបាយដែលបានអនុម័តរួច ដោយថ្នាក់ជាតិ។

ក្រៅពីកង្វះធនធានការវាយតម្លៃក៏បានណែនាំថា ការប្រតិបត្តិការកាត់បន្ថយគ្រោះមហន្តរាយនាពេលបច្ចុប្បន្ន គឺមានការលំបាកក្នុងការអនុវត្តនៅគ្រប់កម្រិតទាំងអស់។ នៅថ្នាក់ជាតិ NCDM មិនបានជួបប្រជុំគ្នាទៀងទាត់ ហើយជាច្រើនឆ្នាំកន្លងមកនេះ ក្រសួង និងភាគីពាក់ព័ន្ធបានធ្វើការជួបជុំ និងសហការគ្នាតែនៅក្នុងករណីសង្គ្រោះបន្ទាន់ និងគ្រាមានគ្រោះមហន្តរាយកើតឡើងតែប៉ុណ្ណោះ។ នៅកម្រិតថ្នាក់ក្រោមជាតិ មានស្ថានភាពហាក់ដូចជាកាន់តែលំបាកដោយសង្កេតឃើញថា អង្គភាពគ្រប់គ្រងគ្រោះមហន្តរាយនៅកម្រិត ខេត្ត ស្រុក ឃុំ (PCDM-DCDM-CCDM) ដែលជាតួអង្គជួរមុខក្នុងការប្រឈមនឹងផលប៉ះពាល់ដោយផ្ទាល់ចំពោះកិច្ចការសង្គ្រោះបន្ទាន់ និងគ្រោះមហន្តរាយនោះ ដែលជាក់ស្តែងស្ថាប័នទាំងនេះ នៅមានសមត្ថភាពទាបខ្លាំងជាងស្ថាប័នថ្នាក់ជាតិនៅឡើយ។ សមត្ថភាពជាក់ស្តែងខុសគ្នាគួរឱ្យកត់សម្គាល់ ពីវិស័យមួយទៅវិស័យមួយផ្សេងទៀតដោយជាធម្មតាតែងតែពឹងផ្អែកជាចំបងទៅលើវត្តមាន ឬ អវត្តមាននៃភាគីពាក់ព័ន្ធខាងក្រៅ។

ការបង្កើតក្រុមការងារពិសេសថ្មីមួយរបស់រដ្ឋាភិបាលស្តីពី ការឆ្លើយតបបន្ទាន់ និងការស្តារឡើងវិញតាមរយៈដំណោះស្រាយរបស់នាយករដ្ឋមន្ត្រីនៅថ្ងៃទី 4 ខែកក្កដា ឆ្នាំ2014 អាចជាវេទិកាដ៏មានសារៈសំខាន់មួយ ក្នុងការដោះស្រាយបញ្ហាការសម្របសម្រួលទាំងនៅកម្រិតជាតិនិងកម្រិតថ្នាក់ក្រោមជាតិ។

## ២.៣.៣. ឋិជ្ជភាពគោលនយោបាយ និងការអនុវត្តកិច្ចគាំពារសង្គម

តាមការពិនិត្យលើឯកសារដែលមានស្រាប់ ព្រមទាំងរបាយការណ៍វាយតម្លៃមួយចំនួន បានបង្ហាញថា ប្រទេសកម្ពុជាមានភាពរីកចម្រើនច្រើនលើ ការបញ្ជ្រាបកម្មវិធីកិច្ចគាំពារសង្គមចូលរួមសន្ទនាផ្នែកគោលនយោបាយ និងការសម្របសម្រួលដល់ការកសាងសមត្ថភាព ដែលផលលំបាកទាំងឡាយកន្លងមកនៅតែបន្ត សម្រាប់ក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) ក្នុងការគៀងគរភាពជាម្ចាស់សម្រាប់រដ្ឋាភិបាលទាំងមូល និងដាក់ចូលកម្មវិធីគាំពារសង្គមទៅក្នុងក្រសួងពាក់ព័ន្ធ។ បើទោះបីជាមានការផ្សព្វផ្សាយនូវយុទ្ធសាស្ត្រជាតិគាំពារសង្គម (NSPS) ដែលបានរៀបចំឡើងដោយ CARD ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ តែការយល់ដឹងពីកិច្ចគាំពារសង្គមគឺ នៅមានកម្រិតទាបនៅឡើយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលប្រហែលបណ្តាលមកពីកំរិតទាបនៃលទ្ធភាពហិរញ្ញវត្ថុ វិសហវិមជ្ឈការ ក្នុងការវិនិយោកទៅលើវិស័យកិច្ចគាំពារសង្គមនេះ។

ដូចគ្នានេះដែរ សមត្ថភាពធនធានមនុស្ស គឺនៅមានការខ្វះខាតនៅឡើយ ដើម្បីប្រឈមនឹងភាពស្មុគស្មាញ និងមហិច្ឆតា នៃរបៀបវារៈសកម្មភាព ដែលបានចែងនៅក្នុងNSPS។ កង្វះខាតនេះមានន័យថា រដ្ឋាភិបាលផ្តល់ថវិកាជាតិត្បិតត្បៀត (ដោយសារតែមូលដ្ឋានពន្ធនៅចង្អៀត និងមានភាពទន់ខ្សោយនៅក្នុងការប្រមូលប្រាក់ចំណូល) ដែលវាជា ការរារាំងដល់លទ្ធភាពរបស់ CARD ក្នុងការសម្រេចនូវបេសកកម្មរបស់ខ្លួន។ បញ្ហាទាំងអស់នេះលើកឡើងជាសំណួរថាតើ គោលដៅនៃកិច្ចគាំពារសង្គមដែលមានចែងនៅក្នុង NSPS អាចសម្រេចបាននៅចុងបញ្ចប់នៃវដ្តនៃយុទ្ធសាស្ត្រនេះនាឆ្នាំ 2015 ដែរឬទេ ? ហើយនៅដំណាលគ្នានោះដែរ តើការរៀបចំវដ្តនៃយុទ្ធសាស្ត្របន្ទាប់យ៉ាងដូចម្តេច ?។

## ២.៣.៤. ការបន្សាំកិច្ចគាំពារសង្គម (ការធ្វើសមាហរណកម្មរវាងកិច្ចគាំពារសង្គម ការបន្សាំការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយ)

ភាពជាសកល សំណួរដដែល ដែលត្រូវឆ្លើយតបគឺ កម្រិតនៃការធ្វើសមាហរណកម្មរវាងកិច្ចគាំពារសង្គម ការបន្សាំការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ។ តាមរយៈការពិនិត្យលើឯកសារជាច្រើនបានបង្ហាញថា កិច្ចគាំពារសង្គមត្រូវបានដាក់បញ្ចូលទៅក្នុង ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ដែលកិច្ចគាំពារសង្គមគឺ ជាបញ្ហាអន្តរវិស័យមួយក្នុងចំណោមបញ្ហាអន្តរវិស័យផ្សេងៗទៀត ដូចជា យេនឌ័រ ការស្រាវជ្រាវ ការអប់រំការយល់ដឹងនិងការទំនាក់ទំនង តាមដាននិងវាយតម្លៃ ការផ្តល់ហិរញ្ញប្បទានអាកាសធាតុ និង ការគ្រប់គ្រងចំណេះដឹង ប៉ុន្តែ CCCSP ក៏មិនបានបង្ហាញផងដែរ ពីរបៀបធ្វើសមាហរណកម្ម និងរបៀបដែលនឹងត្រូវគៀងគរការចូលរួមនៃកិច្ចគាំពារសង្គមប្រកបដោយប្រសិទ្ធិភាព។

ដូចគ្នានេះដែរ តឹកតាងដែលបានរកឃើញតាមរយៈការពិនិត្យលើឯកសារដែលមានស្រាប់ ជាការកត់សំគាល់មួយនៅក្នុងឯកសារបានបញ្ជាក់ថា គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុត្រូវបានបញ្ចូលក្នុង NSPS ឆ្នាំ2011 ហើយការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានទទួលស្គាល់ថា ជាសសរស្តម្ភដ៏សំខាន់មួយសម្រាប់កិច្ចគាំពារសង្គម ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សមាហរណកម្មនេះមិនមានអ្វីលើសពីគោលនយោបាយ និងឯកសារគម្រោងនោះទេ។ ដើម្បីអោយការបន្សាំប្រកបដោយប្រសិទ្ធិភាព (ព្រមទាំងការទប់ស្កាត់) លើការប្រែប្រួលអាកាសធាតុ គួរត្រូវយកចិត្តទុកដាក់ ប៉ុន្តែនាពេលនេះនៅមិនទាន់មានដាក់ចេញនូវផែ្នកសកម្មភាពជាក់លាក់ ដើម្បីអនុវត្តឯកសារយុទ្ធសាស្ត្រកិច្ចគាំពារសង្គមនៅឡើយ។

កន្លងមក ការធ្វើសមាហរណកម្ម ការកាត់បន្ថយគ្រោះមហន្តរាយ និងការបន្សាំការប្រែប្រួលអាកាសធាតុ នៅតែមានការលំបាកនៅឡើយ។ តាមរយៈលទ្ធផលនៃការវិភាគស្នើឡើងថាការធ្វើសមាហរណកម្មបច្ចុប្បន្ននេះ គួរផ្សាភ្ជាប់ទំនាក់ទំនងក្នុងការរៀបចំគោលនយោបាយ និងការអនុវត្តន៍ រវាងផលប៉ះពាល់នៃគ្រោះមហន្តរាយ និងការផ្លាស់ប្តូរអាកាសធាតុដែលជាហេតុការណ៍ប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចកម្ពុជា (ហើយក៏ដូចជាប៉ះពាល់ទៅលើជីវភាពរស់នៅរបស់ប្រជាជន)។

ជាសរុបមក សមាហរណកម្មរវាងគោលនយោបាយក្នុងវិស័យទាំងបីគឺ នៅមានទំនាក់ទំនងទន់ខ្សោយនៅឡើយ។ ជំហានចុងក្រោយក្នុងការវិភាគនេះ គឺដើម្បីពិនិត្យមើលការលើកឡើងក្នុងឯកសាររដ្ឋាភិបាល ដើម្បីរៀបចំជាទស្សនាទានលើការបន្សាំកិច្ចគាំពារសង្គម។ យោងតាមការលើកឡើងនៅក្នុងឯកសារ CCCSP នៅត្រង់គោលបំណង ទី៦ គឺៈ "លើកកម្ពស់ការបន្សាំកិច្ចគាំពារសង្គម និងវិធីសាស្ត្រដែលមានការចូលរួមក្នុងការកាត់បន្ថយការបាត់បង់ និងការខូចខាតដោយសារតែការប្រែប្រួលអាកាសធាតុ"។ បើពិនិត្យមើលអោយបានហ្មត់ចត់បន្ថែមទៀត នៅក្នុងបញ្ជីសកម្មភាពដែលត្រូវបានលើកឡើងសម្រាប់អនុវត្តការបន្សាំកិច្ចគាំពារសង្គមក្នុងបរិបទនៃ CCCSP បង្ហាញថាបើទោះជាមានសកម្មភាពជាច្រើន ដែលមិនមែនជាសកម្មភាពនៃការបន្សាំកិច្ចគាំពារសង្គម ដោយសំដៅលើរបៀបវារៈទូលំទូលាយដែលប្រហាក់ប្រហែលទៅនឹង'សកម្មភាពសហវិមជ្ឈការ' ជាដាង។

# ៣. សង្ខេបលទ្ធផលសិក្ខាសាលាស្តីពីទ្រឹស្តីនៃការផ្លាស់ប្តូរ

ផ្នែកនេះបង្ហាញពីសេចក្តីសង្ខេបលទ្ធផលសិក្ខាសាលាថ្នាក់ជាតិចំនួនពីរ លើការបន្សាំកិច្ចគាំពារសង្គម (ASP) និងសិក្ខាសាលាស្តីពីទ្រឹស្តីនៃការផ្លាស់ប្តូរ (ToC) ដែលត្រូវបានរៀបចំឡើងក្រោមគំនិតផ្តួចផ្តើមរបស់ UNDP-CO។ សម្រាប់ព័ត៌មានលំអិតនៃសិក្ខាសាលាទាំងនេះ គឺមាននៅក្នុងរបាយការណ៍របស់ Manda និងYamamoto (ឆ្នាំ2014) ដែលមានភ្ជាប់នៅឧបសម្ព័ន្ធទី2 ។

## ៣.១ បញ្ហាសំខាន់ៗ

សិក្ខាសាលាថ្នាក់ជាតិចំនួនពីរ បានរៀបចំឡើងសម្រាប់អ្នកចូលរួមពីក្រុមផ្សេងគ្នា ដែលសិក្ខាសាលាលើកទី១គឺជាមួយបុគ្គលិករបស់អង្គការ UNDP និងសិក្ខាសាលាលើកទី២ជាមួយភាគីពាក់ព័ន្ធថ្នាក់ជាតិ រួមមានបុគ្គលិកមកពីក្រសួងពាក់ព័ន្ធអ្នកបច្ចេកទេស និងដៃគូហិរញ្ញវត្ថុ។ សិក្ខាសាលាទាំងពីរនេះធ្វើឡើងដើម្បីពង្រឹងនូវលទ្ធផលនៃការសិក្សាវិភាគស្ថានភាពនៃការបន្សាំ

កិច្ចគាំពារសង្គម។ គោលដៅចម្បងគឺដើម្បីកំណត់ផ្លូវឆ្ពោះទៅរកការផ្លាស់ប្តូរដែលអាចឈានទៅរៀបចំយុទ្ធសាស្រ្តបន្សាំកិច្ចគាំពារសង្គមនិងការអនុវត្តនៅក្នុងប្រទេសកម្ពុជា។

បញ្ហា និងសេចក្តីសន្និដ្ឋានជាច្រើនត្រូវបានកំណត់តាមរយៈសិក្ខាសាលាទាំងពីរនេះ។

### ៣.១.១. សិក្ខាសាលាពិគ្រោះយោបល់ជាមួយបុគ្គលិកអង្គការ UNDP

ខណៈមានការពេញចិត្តកាន់តែប្រសើរឡើង ទៅលើទស្សនាទាន ASP។ វាច្បាស់ណាស់ថា ការលើកទឹកចិត្តស្ថាប័ន មិនចាំបាច់ត្រូវការសម្របសម្រួលសម្រាប់កម្មវិធីអនុវត្តនានានៅក្នុងអង្គការ UNDP ទេ។ ភាពសំខាន់មួយ សំរាប់ការធ្វើសមាហរណកម្មគឺការប្រើប្រាស់ពាក្យ ដោយសារអ្នកជំនាញមកពីផ្នែកខុសៗគ្នាប្រើប្រាស់ពាក្យផ្សេងៗគ្នា ចំពោះរឿងស្រដៀងគ្នា។ សិក្ខាសាលាបានណែនាំមិនអោយសង្កត់ធ្ងន់ លើការប្រើប្រាស់ពាក្យបន្សាំគាំពារសង្គម ប៉ុន្តែផ្តោតសំខាន់ទៅលើគោលការណ៍នៃការធ្វើសមាហរណកម្ម និងអនុវត្តពិតប្រាកដក្នុងកម្មវិធីរបស់ខ្លួនដែលគំនិតផ្តួចផ្តើម និងការគោលនយោបាយទាំងនោះ គឺឆ្លុះបញ្ចាំងពីរបៀបធ្វើការថ្មីមួយ។

ចំណុចគួរពិចារណាសំខាន់មួយទៅលើ គំនិតផ្តួចផ្តើមការបន្សាំកិច្ចគាំពារសង្គម គឺត្រូវធ្វើការវាយតម្លៃលើកទឹកចិត្តដល់ការធ្វើសមាហរណកម្មទាំងនៅកម្រិតកម្មវិធីជាតិ ថ្នាក់មូលដ្ឋាន កម្រិតស្ថាប័ន និងកម្រិតកម្មវិធីផងដែរ។ ក្នុងបរិបទទាំងនេះ ការលើកទឹកចិត្តមួយដ៏សំខាន់គឺ ផ្តល់ហិរញ្ញវត្ថុ និងមូលនិធិសហគមន៍សម្រាប់ការបន្សាំបម្រែបម្រួលអាកាសធាតុ ឬការកាត់បន្ថយគ្រោះមហន្តរាយ ដែលត្រូវយកចិត្តទុកដាក់ធ្វើ ទោះជាយ៉ាងណាយើងមើលឃើញថា វាជាវិធានការសម្រាប់ រយៈពេលខ្លីតែប៉ុណ្ណោះ។ ជាក់ស្តែង ការចាំបាច់មួយត្រូវបង្កើតជាកម្មវិធីដែលអាចសម្រេចបានសម្រាប់ រយៈពេលខ្លី មធ្យម និងរយៈពេលវែងទៅតាមបរិបទនៃប្រទេស។ ការទទួលស្គាល់ថា ASP នៅមិនទាន់ត្រូវបានទទួលយកជាទស្សនាទាន ដែលអាចសំរេចបានមួយសំរាប់រដ្ឋាភិបាល ហេតុដូច្នេះហើយ ជាដំបូងអង្គការUNDP គួរតែផ្តោតទៅលើការតស៊ូមតិ ក្នុងការបញ្ជ្រាបទស្សនាទាន ក៏ដូចជាការធ្វើសមាហរណកម្មនេះឱ្យកាន់តែល្អប្រសើរ ។ ជាពិសេសអង្គការ UNDP គួរព្យាយាមរៀបចំចងក្រងឯកសារនិងវេទិកាសម្រាប់គំនិតផ្តួចផ្តើម ASP ហើយគួរបញ្ចូលនូវការចងក្រងករណីសិក្សាវិភាគសេដ្ឋកិច្ចសម្រាប់ ASP ដែលរដ្ឋាភិបាលអាចយកមកអនុវត្តបាន។ ការពង្រឹងសមត្ថភាពបុគ្គលិកនៅក្នុងអង្គការ UNDPគឺមានសារៈសំខាន់ណាស់ ដើម្បីអាចមានកម្រិតកាន់តែប្រសើរឡើងចំពោះការចូលរួមកំរិតគោលនយោបាយនៃយុទ្ធសាស្រ្តថ្មី ដែលនឹងផ្ទុយពីកម្មវិធីដែលខ្លួន។ ការប្រតិបត្តិ ទទួលយកទស្សនាទាន ASP គឺទាក់ទងនឹងការផ្លាស់ប្តូររបៀបធ្វើការងាររបស់ពួកយើង ហើយក្នុងករណីនេះ អង្គការ UNDP អាចធ្វើការបញ្ចូលគោលគំនិត ASP ទៅក្នុងការអនុវត្តន៍កម្មវិធី ដោយមិនចាំបាច់ជំរុញក្រុមការងារឱ្យពួកគេត្រូវតែធ្វើការរួមគ្នាទូទាំងក្រុមនោះឡើយ។

សេដ្ឋកិច្ចនយោបាយ គឺជាចំណុចស្នូលនៃបញ្ហាស្ថាប័នហើយអង្គការ UNDP ចាំបាច់ធ្វើការអង្កេតបន្ថែមទៀត ទៅលើកត្តាជម្រុញឱ្យមានការផ្លាស់ប្តូរ ក្នុងគោលបំណាងឈានទៅដល់ការផ្លាស់ប្តូរ ឬលទ្ធផលដែលចង់បាន។ វិភាគអំពីរបៀបនៃការផ្លាស់ប្តូរ ដែលអាចផ្សព្វផ្សាយក្នុងចំណោមថ្នាក់ដឹកនាំនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត។ ភាពជាម្ចាស់របស់រដ្ឋាភិបាលលើទស្សនាទាន ASP គឺមានសារៈសំខាន់ខ្លាំងណាស់។ បច្ចុប្បន្ននេះ រដ្ឋាភិបាលបានចាត់កម្មវិធីគាំពារសង្គមជាកម្មវិធីដែលជម្រុញដោយម្ចាស់ជំនួយ ដូច្នេះហើយទស្សនៈនេះ ចាំបាច់ត្រូវតែផ្លាស់ប្តូរ។

ជារួម គឺត្រូវចាប់ផ្តើមអនុវត្តគម្រោងតូចមួយ ប៉ុន្តែត្រូវមានតួអង្គសំខាន់នៃស្ថាប័នរដ្ឋាភិបាលចូលរួមអនុវត្ត ដើម្បីចងក្រងជាករណីសិក្សាមួយជាការរៀនសូត្រយកទៅបង្កើតកម្មវិធី ក្នុងស្ថាប័នរបស់ខ្លួនបាន ឬដាក់បញ្ចូលវិធីសាស្រ្ត ASP ទៅក្នុងកម្មវីធីរបស់ពួកគេ។

### ៣.១.២. សិក្ខាសាលាពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធខាងក្រៅ (រួមទាំងមន្រ្តីរដ្ឋាភិបាល)

ចំណុចខ្វះខាតមួយចំនួនត្រូវបានទទួលស្គាល់។ ជាឧទាហរណ៍ទស្សនាទាននីមួយៗនៃកិច្ចគាំពារសង្គម ការកាត់បន្ថយគ្រោះមហន្តរាយ និងការបន្សាំការប្រែប្រួលអាកាសធាតុ គឺនៅថ្មីនៅឡើយសម្រាប់ប្រទេសកម្ពុជា។ ស្ថាប័នផ្សេងៗគ្នា ប្រើពាក្យខុសៗគ្នា ហើយការយល់ដឹងពីទស្សនាទានក៏ខុសប្លែកគ្នាផង

ដែរ។ ស្ថាប័នទទួលខុសត្រូវលើការសម្របសម្រួល និងស្ថាប័នអនុវត្តលើប្រធានបទនីមួយៗមានអាណត្តិក៏ខុសគ្នា ក៏ដូចជាពេលវេលាផ្សេងៗគ្នាដើម្បីសម្រេចគោលដៅរបស់ពួកគេដូច្នេះ ហើយ វាមានការលំបាកក្នុងការឈានទៅបង្កើតស្ថាប័នសម្របសម្រួលថ្នាក់ជាតិមួយសំរាប់ ASP ។ ក្នុងបរិបទនេះ គឺមានភាពចាំបាច់ក្នុងការបង្កើតកម្មវិធី និងចាប់ផ្តើមធ្វើការជាមួយស្ថាប័នដែលមានស្រាប់ និងយន្តការសម្របសម្រួលដែលមានស្រាប់។

ជាសារ គឺថា "ASP គឺជាវិធីធ្វើការរួមគ្នាមួយ", "ASP នឹងបង្កើនប្រសិទ្ធិភាព និងប្រសិទ្ធិផលក្នុងការសម្រេចលទ្ធផលនៃកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលដែលត្រូវប្រើសម្រាប់សកម្មភាពផ្សេងៗមួយចំនួននៅក្នុងវិស័យពាក់ព័ន្ធ ដូចជាការកសាងសមត្ថភាពដល់បុគ្គលិក" ដែលជាប្រយោជន៍ក្នុងការលើកទឹកចិត្តដល់ការសហការរវាងក្រសួងពាក់ព័ន្ធ និងភ្នាក់ងារទាំងឡាយណា ដែលមានបំណងក្នុងការទទួលយកក្របខ័ណ្ឌការងារ ASP ។

បច្ចុប្បន្ននេះ ការរួមចំណែកហិរញ្ញវត្ថុពីភ្នាក់ងារអភិវឌ្ឍន៍ ជាប្រភពដ៏សំខាន់សម្រាប់កិច្ចគាំពារសង្គមការកាត់បន្ថយគ្រោះមហន្តរាយ និងកម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ដើម្បីបង្កើតភាពជាម្ចាស់ របស់រដ្ឋាភិបាលសម្រាប់កម្មវិធីអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព តួយ៉ាង ASP នឹងត្រូវផ្ទេរអោយបានរលូនទៅក្នុងកម្មវិធីកិច្ចគាំពារសង្គម កម្មវិធីកាត់បន្ថយគ្រោះមហន្តរាយ និងកម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុ ដល់រដ្ឋាភិបាលនាពេលអនាគត។ កម្មវិធី ASP ( ក្នុងចំណោមកម្មវិធីផ្សេងៗទៀត ) ដែលរដ្ឋាភិបាលអាចបន្តការគាំទ្រ និងអាចគ្រប់គ្រងបានដោយរដ្ឋាភិបាល ទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស។

តាមរយៈការពិគ្រោះយោបល់នេះ គឺបានរកឃើញថា វាចាំបាច់ត្រូវតែពិភាក្សាគ្នាលើការបង្កើតកម្មវិធី ASP នៅតាមសហគមន៍ ( ឧទាហរណ៍ ផែនការអភិវឌ្ឍន៍ឃុំសង្កាត់ ) ដែលនឹងបង្កើនភាពជាម្ចាស់ក្នុងចំណោមភាគីពាក់ព័ន្ធក្នុងមូលដ្ឋាន ដែលពួកគេជាអ្នកទទួលខុសត្រូវចំបងក្នុងការអនុវត្ត។

# ៤. ផែនទីបង្ហាញផ្លូវសម្រាប់រៀបចំការបន្សាំកិច្ចគាំពារសង្គមនៅកម្ពុជា

## ៤.១. គោលការណ៍សំខាន់ៗ

ការវិភាគស្ថានភាព បានជួយកំណត់នូវគោលការណ៍សំខាន់បីដែលចាំបាច់ ដើម្បីធានាឱ្យបាននូវភាពជោគជ័យឆ្ពោះទៅមុខនៃកម្មវិធី ASP ។

១ ASP ជាការរួមចំណែកមួយទៅនឹងគោលនយោបាយការអភិវឌ្ឍន៍រាជរដ្ឋាភិបាលកម្ពុជា៖ ដើម្បីបង្កើនឱកាសបង្កើតកម្មវិធី ASP នោះ ជាមធ្យោបាយគឺត្រូវស្វែងយល់ និងត្រូវជម្រុញការបញ្ជ្រៀតចូលទៅក្នុងកម្មវិធី និងកិច្ចអន្តរាគមន៍នានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវរៀបចំឡើង និងត្រូវអនុវត្ត។ ជាពិសេស ការរៀបចំកម្មវិធី ASP គួរតែត្រូវបានបង្ហាញ និងតស៊ូមតិដើម្បីអាចរួមចំណែកក្នុងគោលនយោបាយអភិវឌ្ឍន៍រាជរដ្ឋាភិបាលកម្ពុជា ដែលមានកំណត់នៅក្នុង NSDP 2014-2019 ។

២ ASP ជាវិធីសាស្ត្រអន្តរវិស័យដែលត្រូវសម្របសម្រួលដោយស្ថាប័នដែលមានស្រាប់៖ ASP គឺសំដៅលើការរួមបញ្ចូលកិច្ចសហប្រតិបត្តិការ និងការសហការរវាងសហគមន៍ការអនុវត្ត និងទីភ្នាក់ងារអនុវត្ត។ ដូច្នេះ គឺមិនអាចត្រូវបង្កើតនូវក្រសួងមួយ ឬទីភ្នាក់ងារណាមួយឡើយ។ ត្រូវតែដឹងថាហិរញ្ញប្បទានដែលបានផ្តល់ និងអនុវត្តជាមួយវិធីសាស្ត្ររៀបចំកម្មវិធីអន្តរវិស័យហើយវាត្រូវការរៀបចំចាត់ចែងដោយស្ថាប័នដែលមានស្រាប់។

៣ ASP ត្រូវចាប់ផ្តើមជម្រុញតាមរយៈឯកទត្តជន៖ ដោយវាជាវិធីសាស្ត្រថ្មី ដូចនេះ ASP ត្រូវចាប់ផ្តើមដំបូង ត្រូវតែមានការគាំទ្រ និងជម្រុញដោយឯកទត្តជននៅក្នុងជួររដ្ឋាភិបាល។ ឯកទត្តជនទាំងនេះនឹងត្រូវបានជ្រើសរើសយ៉ាងប្រុងប្រយ័ត្ននៅក្នុងស្ថាប័នទាំងបី ដែលទទួលបន្ទុកលើកិច្ចគាំពារសង្គម ការកាត់បន្ថយគ្រោះមហន្តរាយ និងការបន្សាំការប្រែប្រួល

អាកាសធាតុ។ អង្គការ UNDP នឹងត្រូវដើរតួនាទីយ៉ាងសំខាន់ជា "អន្តរការីដែលប្រកបដោយភាពស្មោះត្រង់" ដើម្បីគាំទ្រ និងជួយសម្រួលដល់ការផ្តួចផ្តើមកម្មវិធីអន្តរវិស័យនេះ។

## ៤.២. បញ្ញត្តិណែនាំ

ដោយផ្អែកលើការរកឃើញពីទ្រឹស្តីការផ្លាស់ប្តូរ និងបទពិសោធន៍ទូទៅជាច្រើនដែលទទួលបាន តាមរយៈការស្រាវជ្រាវផ្សេងៗទាក់ទងនឹង ASP (ឧទាហរណ៍ Davies et al 2013)។ ឯកសារយុទ្ធសាស្ត្របានទទួលស្គាល់ថាទំនងនឹងទទួលបានជោគជ័យ។ យុទ្ធសាស្ត្រ ASP មួយគួរត្រូវមានការណែនាំដោយសំណុំច្បាប់ច្បាស់លាស់មួយ។ ច្បាប់ណែនាំទាំងនេះរួមមានដូចខាងក្រោម៖

១. ការកសាងគោលនយោបាយ និងការអនុវត្តន៍ គឺជាដំណើរការវិវត្ត និងដំណើរការច្រំដែលមួយ។ ការធ្វើផែនការរយៈពេលវែងការអនុវត្តន៍ និងការយល់ដឹងផ្នែកហិរញ្ញវត្ថុ គឺចាំបាច់ក្នុងការបង្កើតកន្លែងសម្រាប់ការពិសោធន៍ការទទួលនូវមតិត្រឡប់ និងការសម្រួលអោយកាន់តែល្អប្រសើរថែមទៀត ។

២. និរន្តរភាពនៃ ASP គឺជាមធ្យោបាយធ្វើការមួយដែលទីបំផុតទៅតម្រូវឱ្យមានភាពជាម្ចាស់ដោយរដ្ឋាភិបាល រួមបញ្ចូលទាំងការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុ ។

៣. ការកសាងសមត្ថភាព គឺមានសិទ្ធភាពបំផុតនៅពេលដែលបង្កើនឱកាសសម្រាប់"ការរៀនសូត្រតាមរយៈការអនុវត្តន៍"។ ការរៀបចំ គម្រោងសាកល្បងដោយប្រុងប្រយ័ត្នអាចនឹងក្លាយជាឧបករណ៍ និងដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរៀនសូត្រតាមរយៈការអនុវត្ត។

៤. ភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលគឺជាសមាសភាគដ៏សំខាន់សម្រាប់ការកសាងគោលនយោបាយ ការកសាងសមត្ថភាពស្ថាប័ន និងនិរន្តរភាព។ ភាពជាដៃគូដ៏មានប្រសិទ្ធិភាពទាមទារឱ្យមានការពិភាក្សានូវចំណុចចាប់ផ្តើមសមស្របនូវច្រកចូល និងឯកទេសគួជនដែលពាក់ព័ន្ធក្នុងការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ។

៥. ភាពបត់បែន និងភាពទទួលខុសត្រូវ គឺជាការចាំបាច់ក្នុងការធានាថា ដំណើរការ (នៃការផ្លាស់ប្តូរឆ្ពោះទៅរៀបវារៈ ASP) អាចជាឱកាសសមស្របដើម្បីទាញយកប្រយោជន៍ និងពង្រឹង ក្នុងការបំផុសវិធីថ្មីនៅពេលខាងមុខទៀតដោយការផ្សាភ្ជាប់ទៅនឹងការសម្រេចនូវគោលដៅ គោលបំណង និងគោលការណ៍ដំបូង។

## ៤.៣. ការសន្មត់នានា

លើសពីគោលការណ៍ណែនាំទាំងនេះ ការសន្មត់មួយចំនួនដែលបង្ហាញនូវកត្តាដែលនឹងអាចឱ្យយុទ្ធសាស្ត្រនេះឆ្ពោះទៅមុខ គឺត្រូវបានកំណត់។ ការសន្មត់ទាំងនេះរួមមានដូចខាងក្រោម៖

១. សក្តានុពលអត្ថប្រយោជន៍នៃកម្មវិធី ASP នឹងបង្កើនការទាក់ទាញអារម្មណ៍កាន់តែខ្លាំងឡើងដល់រដ្ឋាភិបាលសង្គមស៊ីវិល និងការយល់ដឹងនៃផលប៉ះពាល់ការផ្លាស់ប្តូរអាកាសធាតុ ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ និងគ្រោះមហន្តរាយធម្មជាតិដ៏ទៃទៀតចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។

២. ភាគីរដ្ឋាភិបាលពាក់ព័ន្ធគឺ ទទួលបានព័ត៌មានថ្មីនិងបានលើកទឹកចិត្តព្រមទាំងអាចធ្វើការលើវិស័យខុសគ្នា "សហគមន៍អនុវត្ត"។

៣. ភស្តុតាងដែល ជាមូលដ្ឋានក្នុងការកសាងគោលនយោបាយ និងការអនុវត្តន៍ដំណើរការល្អ គឺបានផ្តល់ពេលវេលាគ្រប់គ្រាន់ ធនធាន និងព័ត៌មាន គឺអាចទទួលបាន និងបានតម្រង់ទិសឆ្ពោះទៅរកទ្រឹស្តីនៃការផ្លាស់ប្តូរដ៏ល្អមួយ។

៤. ប្រាក់ចំណូលរបស់រដ្ឋាភិបាលនឹងកើនឡើងដោយសារតែកំណើនសេដ្ឋកិច្ច និងសមត្ថភាពប្រមូលពន្ធកាន់តែប្រសើរ ដូច្នេះការបង្កើនថវិកាប្រចាំឆ្នាំច្រើនថែមទៀត សម្រាប់កម្មវិធី ASP ។

៥. កំណែទម្រង់រដ្ឋបាល និងច្បាប់នឹងជួយពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏ដូចជាជួយពង្រឹងរដ្ឋបាលសាធារណៈនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៦. សមាហរណកម្មផែនការ និងការរៀបចំកម្មវិធី គឺជាទូទៅមានភាពងាយស្រួលនៅកម្រិតដែលបានធ្វើវិមជ្ឈការ។ ដូច្នេះរដ្ឋាភិបាលថ្នាក់ក្រោម និងអង្គការសង្គមស៊ីវិលក្នុងស្រុកក្លាយជាដៃគូដែលមិនអាចខ្វះបាន។

៧. ការចំណាយសម្រាប់បុគ្គលិកដៃគូអភិវឌ្ឍន៍ គឺជាទូទៅមានតម្លៃខ្ពស់ ខណៈពេលដែលបុគ្គលិកបច្ចេកទេសនៅក្នុងរដ្ឋាភិបាលទំនងជាសមស្រប ឬមានភាពឋិតថេរជាង។

៨. ជំនួយអភិវឌ្ឍន៍ នឹងមានគ្រប់គ្រាន់សម្រាប់រយៈពេលការធ្វើផែនការឬការអនុវត្ត5ឆ្នាំរួមទាំងជំនួយបច្ចេកទេសផងដែរ ហើយរដ្ឋាភិបាលនឹងទទួលខុសក្នុងការបង្កើនការផ្តល់ហិរញ្ញវត្ថុកាន់តែច្រើនឡើងថែមទៀតក្នុងអំឡុងពេល 5ឆ្នាំបន្ទាប់។

៩. ដៃគូបច្ចេកទេស និងហិរញ្ញវត្ថុ គឺមានការគាំទ្រលើរបៀបវារៈ ASP ។

១០.អង្គការ UNDP រៀបរយក្នុងការដើរតួនាទីនាំមុខចំពោះការសម្របសម្រួលដំណើរការនេះ។

## ៤.៤ ផែនទីបង្ហាញផ្លូវ

ជម្រើសដែលអាចជម្រុញរបៀបវារៈ ASP ឆ្ពោះទៅមុខបាន គឺត្រូវការគាំទ្រលើក្របខ័ណ្ឌកម្មវិធីមួយ ដែលទាក់ទងសំខាន់និង

រូបភាពទី1៖ ដ្យាក្រាមបង្ហាញពីផែនទីបង្ហាញផ្លូវនៃការបន្សាំកិច្ចគាំពារសង្គម

| ឆ្នាំ | 0 | | 1 | | 2 | | 3 | | 4 | | 5 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ខែ | 0-3 | 3-6 | 6-12 | 12-18 | 18-24 | 24-30 | 30-36 | 36-42 | 42-48 | 48-54 | 54-60 | 60-66 | |
| **ដំណាក់កាលដំបូង ( ៦ខែ )** | | | | | | | | | | | | | កំឡុងពេល៥ឆ្នាំលើកទី២ |
| • ភ្ជាប់នឹងពិសោធន៍សង្គមរបស់UNDP | | | | | | | | | | | | | |
| • កំណត់ចំណុចចាប់ផ្តើម និងឯកទគ្គជន | | | | | | | | | | | | | |
| • កំណត់គោលដៅ គោលបំណង និងជម្រើសវិធីសាស្ត្រ | | | | | | | | | | | | | |
| • ស្វែងយល់ពីដំណើរការគោលនយោបាយ | | | | | | | | | | | | | |
| • បង្កើតរបៀបវីរៈផ្សព្វផ្សាយ និងការតស៊ូមតិ | | | | | | | | | | | | | |
| • វិភាគពីសមត្ថភាព និងវាយតម្លៃពីតម្រូវការ | | | | | | | | | | | | | |
| **ដំណាក់កាលទី១ ( ១ឆ្នាំ )** | | | | | | | | | | | | | |
| • បង្កើតការរៀបចំស្ថាប័នប្រកបដោយប្រសិទ្ធិភាព | | | | | | | | | | | | | |
| • ផ្សព្វផ្សាយបង្កើនចំណេះដឹង និងកសាងសមត្ថភាព | | | | | | | | | | | | | |
| - នៅក្នុងUNDP/UN | | | | | | | | | | | | | |
| - នៅក្នុងរាជរដ្ឋាភិបាលកម្ពុជា | | | | | | | | | | | | | |
| • គៀងគរដៃគូបច្ចេកទេស និងហិរញ្ញវត្ថុ និងសង្គមស៊ីវិល | | | | | | | | | | | | | |
| • គៀងគរប្រមូលធនធាន | | | | | | | | | | | | | |
| **ដំណាក់កាលទី២ ( ១ឆ្នាំ )** | | | | | | | | | | | | | |
| • រៀបចំថវិកាគាំទ្រមួយសម្រាប់គម្រោងសាកល្បង ( PPs ) | | | | | | | | | | | | | |
| • រៀបចំក្របខ័ណ្ឌណែនាំមួយ | | | | | | | | | | | | | |
| • រៀបចំគម្រោងសាកល្បងនៅក្នុងស្ថាប័នអនុវត្តទាំងបី | | | | | | | | | | | | | |
| - បង្កើតអោយមានការគាំទ្របច្ចេកទេស | | | | | | | | | | | | | |
| - រៀបចំប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ | | | | | | | | | | | | | |
| • គៀងគរការចូលរួមពីគណៈកម្មាធិការជាតិសំរាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD) | | | | | | | | | | | | | |
| **ដំណាក់កាលទី៣ ( ២ឆ្នាំ )** | | | | | | | | | | | | | |
| • អនុវត្តគម្រោងសាកល្បងទាំង៣ | | | | | | | | | | | | | |
| • ត្រួតពិនិត្យតាមដាន | | | | | | | | | | | | | |
| • ចែករំលែកបទពិសោធន៍ជាបន្ត ( មតិត្រឡប់ ) | | | | | | | | | | | | | |
| • ធ្វើផែនការសម្រាប់៥ឆ្នាំលើកទី២ ( កិច្ចពិភាក្សាដំបូង ) | | | | | | | | | | | | | |
| **ដំណាក់កាលទី៤ ( ១ឆ្នាំ )** | | | | | | | | | | | | | |
| • ការកសាងឯកសារ និងវាយតម្លៃគម្រោងសាកល្បង | | | | | | | | | | | | | |
| • ពង្រីក / កែសម្រួលការរៀបចំគម្រោង / វិសាលភាព / ពង្រីកសកម្មភាព | | | | | | | | | | | | | |
| • មេរៀនដែលទទួលបានសម្រាប់គោលនយោបាយ | | | | | | | | | | | | | |
| • គៀងគរស្ថាប័នរដ្ឋាភិបាលបន្ថែមទៀត | | | | | | | | | | | | | |
| • បញ្ចប់ការធ្វើផែនការសម្រាប់៥ឆ្នាំលើកទី២ | | | | | | | | | | | | | |

ការរៀនសូត្រអំពី ASP របស់អ្នកពាក់ព័ន្ធសំខាន់ៗតាមរយៈការអនុវត្តជាក់ស្តែងនៃគម្រោងអន្តរាគមន៍សាកល្បងរបស់ ASP។ វិធីសាស្ត្រនេះរំពឹងថា ដៃគូរាជរដ្ឋាភិបាលកម្ពុជាបង្កើត និងអនុវត្តគម្រោង/កម្មវិធី ក៏ដូចជាការអនុវត្តជាក់ស្តែងនូវរបៀបដែលអាចអោយបុគ្គល និងស្ថាប័នទទួលយកគំនិតថ្មី និងទស្សនាទាន ASP។ ផ្នែកខាងក្រោមនេះបង្ហាញពីផែនទីបង្ហាញផ្លូវរយៈពេល 5 ឆ្នាំ ដែលត្រូវបានបង្កើតឡើងដើម្បីសម្រេចបាននូវរបៀបវារៈ ASP នេះ។ ផែនទីបង្ហាញផ្លូវនេះត្រូវបានរៀបចំឡើងជាដំណាក់កាលបឋម និងបួនដំណាក់កាលផ្សេងទៀត (ដំណាក់កាលទីមួយទៅដល់ដំណាក់កាលទីបួន) ក្នុងរយៈពេលអនុវត្ត10 ឆ្នាំ។ រូបភាពទី១ខាងក្រោមគឺ ជាការសង្ខេបលើវិធីសាស្ត្រហើយព័ត៌មានលំអិតតាមផ្នែកនីមួយៗនិងមានរាយរាប់ខាងក្រោម។

## ៤.៤.១ ដំណាក់កាលដំបូង (៦ខែ)

បង្កើតស្ថាប័នគាំទ្ររឹងមាំមួយ នៅក្នុងអង្គការ UNDP៖ អង្គការ UNDP នឹងមានតួនាទីយ៉ាងសំខាន់នៅរាល់ដំណើរការក្នុងការគាំទ្រ និងសម្របសម្រួលភាពជាដៃគូ ASP និងឱកាសរៀនសូត្រដកស្រង់បទពិសោធន៍។ ទស្សនាទានពិសោធន៍សង្គម (Social Lab Concept) ដែលបានរកឃើញដោយ UNDP គឺសក្តិសមក្នុងការដើរតួនាទីគាំទ្រ ហើយក៏អាចផ្តល់ជាធនធានសមស្រប (ពោលគឺហិរញ្ញវត្ថុ និងបុគ្គលិក)។ ការគាំទ្រផ្សេងៗពីដៃគូបច្ចេកទេសនិងហិរញ្ញវត្ថុផ្សេងទៀត (ក៏និងអាចទទួលពីសង្គមស៊ីវិល) គឺពិតជាត្រូវការជាចាំបាច់ណាស់។ អង្គការ UNDP ក៏នឹងត្រូវដើរតួនាទីយ៉ាងសំខាន់នៅក្នុងផ្នែកនេះ។

ច្រកចូលដំបូង និងឯកទត្តជន៖ តាមរយៈលទ្ធផលនៃការវិភាគស្ថានភាព និងសិក្ខាសាលាស្តីពីទ្រឹស្តីនៃការផ្លាស់ប្តូរ បានកំណត់នូវចំណុចអាទិភាពពីរគឺ ចំណុចចាប់ផ្តើម និងការកំណត់ឯកទត្តជនក្នុងការជួយបើកដំណើរការការងារនេះ។ ការវិភាគស្ថានភាពបានលើកឡើងថា ចំណុចចាប់ផ្តើមដំបូង គួរមានក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍវិស័យកសិកម្ម និងជនបទ (កិច្ចគាំពារសង្គម) គណៈកម្មការជាតិគ្រប់គ្រង គ្រោះមហន្តរាយ (ការកាត់បន្ថយគ្រោះមហន្តរាយ) ក្រសួងបរិស្ថាន (NCCC/CCCA) និងUNDP។ សិក្ខាសាលាស្តីពីទ្រឹស្តីនៃការផ្លាស់ប្តូរ ក៏បានស្នើដាក់បញ្ចូលការបង្កើតភាពជាដៃគូផ្សេងទៀតនៅដំណាក់កាលដំបូងនៃដំណើរការនេះ។ គួរត្រូវរួមបញ្ចូល NCDDS (ក្រសួងមហាផ្ទៃ) និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ។

ការធ្វើឱ្យច្បាស់នូវគោលដៅ គោលបំណង និងជម្រើសវិធីសាស្ត្រ៖ របៀបវារៈ ASP ត្រូវតែអោយមានភាពសមស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (2014-2018) និងយុទ្ធសាស្ត្រតាមវិស័យ និងផែនការដែលពាក់ព័ន្ធ។ ការវិភាគស្ថានភាព ASP ដោយយក NSDP ជាឯកសារយោងមួយគឺជាចំណុចចាប់ផ្តើមដ៏ល្អ។ ជាជម្រើសវិធីសាស្ត្រ គឺតម្រូវឱ្យមានការពិចារណាដោយប្រុងប្រយ័ត្ន ដែលវាជាចំណុចសំខាន់ក្នុងការកំណត់លើភាពជោគជ័យឬបរាជ័យ។ វាជាការល្អបំផុត គឺត្រូវធ្វើការលើការរៀបចំរបស់ស្ថាប័នដែលមានស្រាប់ ជាជាងព្យាយាមបង្កើតស្ថាប័នថ្មីមួយ។ របៀបវារៈ ASP គឺមានកន្លែងពិសេសមួយដែលត្រូវកំណត់ក្នុងបញ្ហាអន្តរវិស័យ ក៏ដូចជាការជម្រុញភាពជាម្ចាស់ទូលំទូលាយ។

ការយល់ដឹងអំពីដំណើរការគោលនយោបាយ៖ ភាពច្បាស់លាស់នៃគោលដៅ គោលបំណង និងជម្រើសវិធីសាស្ត្រ នឹងតម្រូវឱ្យលម្អិតថែមទៀតលើទ្រឹស្តីនៃការផ្លាស់ប្តូរ ដែលបានផ្តល់លទ្ធផល



Flooded road to Trapaing Thma dam, Pnom Srok district, Banteay MenaChey (Photo Humanitarian Response Forum 2013)

ជាការវិភាគស្ថានភាព ASP និងសិក្ខាសាលាដំបូងស្ដីពីទ្រឹស្ដីនៃការផ្លាស់ប្ដូរ។ ទិដ្ឋភាពនៃការងារនេះ គួរតែដោះស្រាយជាពិសេសលើរបៀបកសាងគោលនយោបាយ នៅក្នុងវិស័យទាំងបីរបស់ស្ថាប័នអនុវត្ត និងការលើកទឹកចិត្ត (សេដ្ឋកិច្ចនយោបាយ) ដែលស្ថាប័នអនុវត្តអាចទទួលយក (ឬក៏មិនទទួលយក) កម្មវិធី ASP ព្រមទាំងធ្វើការសិក្សាផែនទីស្ថាប័ននៃវិស័យទាំងបីរបស់ស្ថាប័នអនុវត្តន៍។ សមាសភាគមួយសំខាន់នៃការសិក្សាផែនទីនេះ គឺត្រូវកំណត់នូវឯកទគ្គជនសក្តានុពលនិងកំណត់នូវដៃគូនៅក្នុងរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍។

ការចងក្រងនូវ «ការអនុវត្តល្អ" គឺជាពន្លឺក្នុងការបង្ហាញលើរបៀបដែលគោលនយោបាយ និងកម្មវិធីអន្តរាគមន៍ ទទួលជោគជ័យរហូតក្លាយទៅជាកម្មវិធីរបស់រដ្ឋាភិបាល ដែលប្រកបដោយនិរន្តរភាព (ឧទាហរណ៍៖ កម្មវិធីកំណត់អត្តសញ្ញាណជនក្រីក្រ មូលនិធិសមធម៌សុខាភិបាល)។ វាមានសារៈប្រយោជន៍ជាពិសេស ក្នុងការកំណត់នូវឧទាហរណ៍ល្អៗទាំងឡាយដែលបានទទួលពីស្ថាប័នអនុវត្តក្នុងវិស័យទាំងបី (CoPs) ។

ការកសាងរបៀបវារៈ ផ្សព្វផ្សាយការយល់ដឹង/ការតស៊ូមតិ៖ការវិភាគស្ថានភាព និងសិក្ខាសាលាបឋមស្ដីពីទ្រឹស្ដីនៃការផ្លាស់ប្ដូរ បានកំណត់ថា ការផ្សព្វផ្សាយ និងសមត្ថភាព គឺជាឧបសគ្គយ៉ាងធំមួយសម្រាប់ស្ថាប័ន និងធនធានមនុស្សដើម្បីអនុវត្តកម្មវិធី ASP នៅក្នុងប្រទេសកម្ពុជា។ ជាទូទៅមានកង្វះខាតលើការផ្សព្វផ្សាយអំពី ASP ទៅដល់ស្ថាប័នរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍។ ការងារដំបូងទាក់ទងនឹងការកសាងសមត្ថភាពគួរផ្ដោតលើ ការលើកកម្ពស់ ការយល់ដឹងអំពីទស្សនាទាន និងការអនុវត្តនៃកម្មវិធី ASP។

វិភាគសមត្ថភាព និងការវាយតម្លៃពីតម្រូវការ៖ ការវិភាគស្ថានភាព និងសិក្ខាសាលាបឋមស្ដីពីទ្រឹស្ដី នៃការផ្លាស់ប្ដូរ ក៏បានសង្កេតឃើញថា សមាសភាគដ៏សំខាន់ទីពីរនៃការកសាងសមត្ថភាពជាដំបូង គឺគួរតែធ្វើការវិភាគសមត្ថភាព និងវាយតម្លៃពីតម្រូវការ ដើម្បីផ្ដល់ជាក្របខ័ណ្ឌមួយសម្រាប់រៀបចំ (ការរៀនសូត្រតាមរយៈការអនុវត្ត) ហើយការពិភាក្សាលម្អិតពីវិធីសាស្ត្រនេះ នឹងមានរៀបរាប់លំអិតថែមទៀតខាងក្រោម។

ការនិយាយនូវភាសាត្រឹមត្រូវ៖បទពិសោធន៍បានពីស្ថាប័នអនុវត្តផ្សេងៗ តួយ៉ាងកិច្ចគាំពារសង្គម បានបង្ហាញថា ទស្សនាទានថ្មីទំនងជានាំឱ្យមានការយល់ច្រឡំ ប្រសិនបើមិនបានកំណត់និងបញ្ជាក់ឱ្យច្បាស់លាស់ពីអត្ថន័យ និងការប្រើប្រាស់ពាក្យអោយបានត្រឹមត្រូវនៅគ្រាដំបូង។ ASP គឺជាទស្សនាទានថ្មីមួយសម្រាប់អ្នកពាក់ព័ន្ធផ្សេងៗ (ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅប្រទេសផ្សេងៗទៀត) ហើយក៏ជាប្រធានបទមួយដែលធ្វើអោយមានការភាន់ច្រឡំ និងប្រកបដោយមហិច្ឆតា។ ជាការសំខាន់ដើម្បីធានាថា ភាគីពាក់ព័ន្ធទាំងអស់គឺ (និយាយភាសាដូចៗគ្នាអំពី ASP) គឺរួមទាំងភាសាអង់គ្លេស និងភាសាខ្មែរ។

## ៤.៤.២ ដំណាក់កាលទី១ (១ឆ្នាំ)

ការរៀបចំស្ថាប័ន៖ ការងារដំបូង គឺការរៀបចំស្ថាប័នប្រកបដោយប្រសិទ្ធិភាព ដែលគួរមានការចូលរួមពីតួអង្គរាជរដ្ឋាភិបាលកម្ពុជា រួមមានស្ថាប័នអនុវត្តលើវិស័យទាំងបី និងបុគ្គលិកអង្គការ UNDP ដែលអាចជជែកពិភាក្សាក្នុងលក្ខណៈក្រៅផ្លូវការ។ ជាការសំខាន់ដែលយើងមិនបង្កើតនូវ គណៈកម្មាធិការសម្របសម្រួលផ្លូវការមួយ ឬស្ថាប័នមួយសម្រាប់ធ្វើតែកិច្ចការនេះទេ។ តែយើងអាចពិចារណាពេលក្រោយប្រសិនបើមានការចាំបាច់ ហើយបើមានភាពសមស្រប។ ជាគំនិតសំខាន់នៅទីនេះ គឺជួយសម្របសម្រួលដល់ការពិភាក្សាក្នុងចំណោម ឬទូទាំងវិស័យទាំងបីដើម្បីគៀងគរការពិភាក្សាអំពីសកម្មភាពលំអិតទាក់ទងនឹងរបៀបវារៈ ASP ។

ការបង្កើនការយល់ដឹង និងការកសាងសមត្ថភាព នៅក្នុងអង្គការ UNDP / ទីភ្នាក់ងារអង្គការសហប្រជាជាតិទាំងឡាយនឹងបង្កើតមូលនិធិស្ថាប័នសំរាប់ការកសាងភាពជាដៃគូ និងការគាំទ្រដល់ភាពជាម្ចាស់ដល់រាជរដ្ឋាភិបាលកម្ពុជា។ ការបង្កើនការយល់ដឹង និងការកសាងសមត្ថភាពដល់រាជរដ្ឋាភិបាលកម្ពុជា គួរអោយមានការចូលរួមពីសំណាក់ទាំងឯកទគ្គជន និងបុគ្គលិកបច្ចេកទេសមកពីស្ថាប័នអនុវត្តទាំងបី។ ការរៀបចំអោយមានជាសិក្ខាសាលាក្រៅផ្លូវការ ទស្សនកិច្ចសិក្សា និងទស្សនកិច្ចក្នុងតំបន់ភូមិភាគត្បូង-ត្បូង និងការជជែកពិភាក្សា គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការបង្កើនការយល់ដឹង និងការកសាងសមត្ថភាព ដោយការផ្ដោតលើការបង្កើនចំណេះដឹងអំពី ASP តាមរយៈឧទហរណ៍ជាក់លាក់។ ជាដំបូង គួរផ្ដោតលើការបង្កើនចំណេះដឹងនិងកសាងសមត្ថភាពទៅដល់អង្គការ UNDP និងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិដែលពាក់ព័ន្ធផ្សេងទៀត។

ភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការ៖ នៅពេលបានរៀបចំស្ថាប័នក្រៅផ្លូវការរួចរាល់ (ឧទាហរណ៍៖ ការទំនាក់ទំនង) នោះ

ការផ្សព្វផ្សាយការយល់ដឹង និងការកសាងសមត្ថភាពបានកំពុងអនុវត្តផងដែរ ជាសំខាន់គឺត្រូវគៀងគរអោយមានការចូលរួមពីដៃគូផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និងសង្គមស៊ីវិលក្នុងការពិភាក្សាក្រៅផ្លូវការអំពីទស្សនាទាន និងគោលការណ៍ ASP។ ដៃគូបច្ចេកទេស និងហិរញ្ញវត្ថុ ដែលមានចំណាប់អារម្មណ៍ អាចចាប់ដៃគូជាមួយអង្គការ UNDP ក្នុងការផ្តល់ធនធានបន្ថែមទៀតហើយចំពោះអង្គការសង្គមស៊ីវិលដែលចាប់អារម្មណ៍ អាចធ្វើជាដៃគូអនុវត្ត។

ការគៀងគរធនធាន គឺត្រូវការពេលវេលាច្រើនក្នុងការគៀងគរធនធាន ព្រមទាំងត្រូវកំណត់នូវជំនួយបច្ចេកទេសសមស្របដើម្បីគាំទ្រដល់ដំណើរការនេះ ហើយត្រូវយល់ថា ដំណើរការនេះទំនងជាត្រូវប្រើប្រាស់កម្លាំង និងពេលវេលាច្រើន។ ការបង្កើតភាពជាដៃគូ គឺពិតជាសំខាន់ណាស់ដើម្បីធានាថា ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស គឺបានទទួលគ្រប់គ្រាន់ និងទាន់ពេលវេលា។

## ៤.៤.៣ ដំណាក់កាលទី២ (១ឆ្នាំ)

ដំណាក់កាលនេះ គឺជាដំណើរការអនុវត្តជាក់ស្តែង "កម្រិតសកម្មភាពអនុវត្តផ្ទាល់" និងត្រូវដាក់ចេញអនុវត្ត។ សន្មត់ថាក្រោយអនុវត្តនូវវិធីសាស្ត្រនេះ គឺបានធ្វើអោយស្ថាប័នបានរៀនសូត្រហើយទីបំផុតទៅរាជរដ្ឋាភិបាលកម្ពុជាមានភាពជាម្ចាស់ដោយសារតាមរយៈការជួយពិតប្រាកដ "បង្ហាត់បង្ហាញជាក់ស្តែង" (ការរៀនសូត្រតាមរយៈការអនុវត្តន៍)។ ការអនុវត្តន៍នេះ គឺបានចងក្រងនូវមេរៀនសម្រាប់ការរៀនសូត្រ ព្រមទាំងជួយពង្រីកបន្ថែមនូវមធ្យោបាយដែលអាចយកទៅអនុវត្តបន្តិចម្តងៗ ក្នុងស្ថាប័នរដ្ឋាភិបាល។ ពាក្យប្រតិបត្តិការក្នុងរឿងនេះគឺ "បន្តិចម្តងៗ"។

ការអភិវឌ្ឍន៍សមត្ថភាព និងការរៀនសូត្រតាមរយៈការអនុវត្តៈ ជម្រើសមួយគឺ ការបង្កើតមូលនិធិ ដើម្បីផ្តល់នូវការគាំទ្រដល់ស្ថាប័នអនុវត្តទាំងបី ក្នុងការរៀបចំគម្រោងសាកល្បងមួយទាក់ទងនឹង ASP។ វិធីសាស្ត្រអនុវត្តនេះ ស្របតាមការរៀបចំស្ថាប័នជាក់ស្តែងរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយមិនអាចបង្កើតក្រុមមួយដែលអាចគ្រប់គ្រងគម្រោងរួមគ្នាទេ។ ជាវិធីសាស្ត្រមួយដែលហាក់ដូចជា ហាក់ដូចជាការបន្ថយមន្ទិលសង្ស័យនៃស្ថាប័នទាំងនោះ ដែលធ្លាប់តែសន្មត់និងរំពឹងទៅលើការទទួលបានធនធានដែលមានប្រភពមូលនិធិពីខាងក្រៅ (ឧទាហរណ៍អង្គការ UNDP) ប្តូរទៅគិតគូរដល់ការគ្រប់គ្រងវាដោយខ្លួនឯងវិញ។

ទោះជាយ៉ាងណាក៏ដោយ នេះមិនមានន័យថា ស្ថាប័នអនុវត្តនីមួយៗ ត្រូវធ្វើការដាច់ដោយឡែកតែម្នាក់ឯងនោះឡើយ។ ដំណើរការគួរត្រូវណែនាំ ដោយក្របខ័ណ្ឌមួយដែលបង្កើតនូវគោលការណ៍ជាមូលដ្ឋាន ដែលស្ថាប័នអនុវត្តជាដៃគូនីមួយៗត្រូវអនុវត្តតាម។ ជាឧទាហរណ៍៖ ស្ថាប័នអនុវត្តនីមួយៗត្រូវស្តែងឡើងថា បានធ្វើការពិគ្រោះយោបល់ ពិតប្រាកដជាមួយស្ថាប័នអនុវត្តពីរផ្សេងទៀត ក្នុងកំឡុងពេលដំណើរការរៀបចំគំរោង។ ការពិភាក្សាក្រៅផ្លូវការរវាងស្ថាប័នអនុវត្តទាំងនេះ គួរតែជាការផ្តល់ឱកាសក្នុងការដោះស្រាយបញ្ហារួមគ្នា និងការចែករំលែកមេរៀនបទពិសោធន៍គ្នាទៅវិញទៅមក។ រឹតតែសំខាន់ថែមទៀត គឺវាជាយន្តការមួយ (ឧទាហរណ៍៖ ដូចជាពិសោធន៍សង្គមរបស់អង្គការUNDP) ក្នុងការគាំទ្រដល់ស្ថាប័នអនុវត្តនីមួយៗ ក្នុងការរៀបចំឧបករណ៍ត្រួតពិនិត្យ និងការវាយតម្លៃសមស្រប។ មានន័យថា គម្រោងសាកល្បងទាំងនេះនឹងក្លាយជាយានមួយ សម្រាប់ការបណ្តុះបណ្តាលតាមរយៈការអនុវត្តការងារកម្រិតខ្ពស់មួយទៀត។

ឧបមាថា ពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំគម្រោង ASP ដែលដំណើរការកសាងផែនការ អាចនិងត្រូវការពេលវេលាប្រហែលជាប្រាំមួយខែ។ បើទោះជាយ៉ាងណានេះក្តី សម្រាប់ដំណាក់កាលនេះ គួរត្រូវទុករយៈពេលមួយឆ្នាំ ចំពោះការអភិវឌ្ឍន៍សមាសភាគលើការកសាងសមត្ថភាពដើម្បីឈានទៅការអនុវត្តដំណើរការគម្រោង។

ភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការ៖ វានឹងមានសារៈសំខាន់លើការពង្រីកការកសាងសមត្ថភាព និងការបង្កើនការយល់ដឹងទៅដល់ដៃគូបច្ចេកទេស និងហិរញ្ញវត្ថុសំខាន់ៗ និងដៃគូសង្គមស៊ីវិល នៅកំឡុងពេលនៃការរៀបចំគម្រោងសាកល្បង ASP។ ជាការសំខាន់ផងដែរក្នុងការគៀងគរការចូលរួមរបស់ NCDDS ក្នុងពេលនេះ ដើម្បីស្វែងរកឱកាសកសាងភាពជាដៃគូសំខាន់ៗជាមួយរដ្ឋបាលថ្នាក់ជាតិ និងក្រោមជាតិ។ ឧទាហរណ៍៖ ស្ថាប័នអនុវត្តមួយ ឬច្រើនអាចត្រូវបានជ្រើសរើសដើម្បីអនុវត្តគម្រោងជាក់លាក់របស់ខ្លួន ដោយការចុះកិច្ចសន្យាជាអង្គការក្រៅរដ្ឋាភិបាលណាមួយ។ (ជាការកត់សម្គាល់៖ គោលការណ៍នៃភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការដែលគួរតែត្រូវបានដោះ

ស្រាយនៅក្នុងក្របខ័ណ្ឌសេចក្ដីណែនាំនានា)។ លើដំណើរការត្រួតពិនិត្យ និងវាយតម្លៃនៅក្នុងគម្រោងសាកល្បងនេះ គឺត្រូវបង្ហាញថា ជាដំណើរការបណ្ដុះបណ្ដាលកម្រិតខ្ពស់តាមរយៈការអនុវត្តការងារ។

ការងារដែលបានរៀបរាប់ខាងលើ នឹងតម្រូវឱ្យមានជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសសមស្រប និងជាបន្តបន្ទាប់ពីអង្គការ UNDP ហើយប្រហែលជាតាមរយៈយន្តការពិសោធន៍សង្គមមួយ។

## ៤.៤.៤ ដំណាក់កាលទី៣ (២ឆ្នាំ)

ការកសាងសមត្ថភាព និងការរៀនសូត្រតាមរយៈការអនុវត្ត៖ ក្នុងដំណាក់កាលនេះគម្រោងសាកល្បងទាំងនេះ នឹងឈានពីការរៀបចំទៅជាដំណាក់កាលអនុវត្តន៍។ ការរៀបចំគម្រោងសាកល្បង គឺសង្កត់ធ្ងន់លើការរៀនសូត្រតាមរយៈការអនុវត្ត។ ការរៀបចំគម្រោងសាកល្បងផងដែរ គឺជាដំណើរការមួយដែលតម្រូវឱ្យមានការ ឬ អាចអោយស្ថាប័នអនុវត្តទាំងបី ចេះដោះស្រាយបញ្ហារួមគ្នា និងការចែករំលែកព័ត៌មានបទពិសោធន៍ពីគ្នាទៅវិញទៅមក។ នេះជាទិដ្ឋភាពដ៏សំខាន់បំផុតនៅក្នុង ការអនុវត្តជាក់ស្ដែងនូវប្រព័ន្ធត្រួតពិនិត្យមួយដែលផ្ដល់នូវការចងក្រងឯកសារ និងមតិត្រឡប់ដ៏មានប្រសិទ្ធិភាពសម្រាប់ស្ថាប័នអនុវត្តនីមួយៗចាត់ចែងគម្រោងរបស់ពួកគេ។

សំខាន់ផងដែរ ក្នុងការអញ្ជើញអ្នកសង្កេតការណ៍ពីស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាផ្សេងៗ ព្រមជាមួយដៃគូបច្ចេកទេស និងហិរញ្ញវត្ថុដ៏ទៃទៀត ដើម្បីសង្កេតមើលពីដំណើរការអនុវត្តគម្រោងសាកល្បងនេះ។ លទ្ធផលអាចសំរេចបានតាមរយៈមធ្យោបាយជាច្រើន រួមមានដូចជា ការរៀបចំដំណើរទស្សនកិច្ចសិក្សានិង ឬការចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់រៀងរាល់ 6 ខែ ដែលក្នុងសិក្ខាសាលានោះ ស្ថាប័នអនុវត្តទាំងបីនឹងរាយការណ៍អំពីវឌ្ឍនភាពគម្រោងសាកល្បងរបស់ខ្លួន។



A group of villagers on a flooded field in Tanot Village (Humanitarian Response Forum 2013)

## ៤.៤.៥ ដំណាក់កាលទី៤ ( ១ឆ្នាំ )

ការចងក្រងឯកសារ និងវាយតម្លៃ៖ ត្រូវលះបង់ពេលវេលាច្រើន ដោយការយកចិត្តទុក និងកិច្ចខំប្រឹងប្រែងដោយផ្តោតទៅលើ ការវាយតម្លៃ និងការចងក្រងឯកសារ នៅដំណាក់កាលចុង ក្រោយនៃគម្រោងសាកល្បង។ ឯកសារវាយតម្លៃ និងឯកសារ ដែលបានចងក្រងផ្សេងៗទៀត និងជួយផ្តល់ជាព័ត៌មានសម្រាប់ កិច្ចពិភាក្សាជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូបច្ចេកទេស និងហិរញ្ញវត្ថុសំខាន់ៗ ដើម្បីទទួលបានមូលនិធិរួមគ្នាក្នុងការ ពង្រីកគម្រោងសាកល្បងទាំងនោះ ដែលជាផ្លូវឆ្ពោះទៅដល់ការ ពង្រីកការអនុវត្តសកម្មភាពច្រើនថែមទៀត។ វាមិនមានភាព ចាំបាច់ទេដើម្បីសន្មត់ថា គម្រោងសាកល្បងលើវិស័យទាំងបី ត្រូវតែពង្រីកសកម្មភាពច្រើនថែមទៀតនោះទេ។ គឺចាំបាច់ត្រូវ គៀងគរការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ផែនការ និងក្រសួងមហាផ្ទៃ ( NCDD ) ក្នុងការពិភាក្សាអំពីរបៀប ផ្តល់ហិរញ្ញប្បទាន និងការពង្រីកសកម្មភាពអនុវត្តសមស្រប។ ការពិភាក្សាទាំងនោះ ទំនងត្រូវផ្តោតផងដែរចំពោះការបន្តឧបត្ថម្ភ គាំទ្រមួយចំនួនរបស់អង្គការ UNDP (ប្រហែលជាដៃគូបច្ចេកទេស និងហិរញ្ញវត្ថុផ្សេងទៀត) នៅតែបន្ត ការចូលរួមទាក់ទងនឹង ការពង្រីកទំហំថវិកាបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាការ ឆ្ពោះទៅរកភាពជាម្ចាស់ពេញលេញដោយរាជរដ្ឋាភិបាលកម្ពុជា។

ការពង្រីក/ការកែសម្រួលគម្រោងសាកល្បង៖ តាមរយៈការវាយ តម្លៃគម្រោងសាកល្បង និងការចងក្រងឯកសារ គឺមានសារៈ សំខាន់ណាស់ ក្នុងការផ្តល់ព័ត៌មានសម្រាប់កែតម្រូវណាមួយ ដែលចាំបាច់ ដែលត្រូវការដើម្បីជួយលើការកសាងនូវនិរន្តរភាព នៃការពង្រីកសកម្មភាព អន្តរាគមន៍របស់គម្រោងឱ្យទទួលបាន ជោគជ័យ។ ឧបមាថា៖ គម្រោងសាកល្បង បានអនុវត្តយ៉ាងល្អ ហើយអាចពង្រីកបាន ( ឧទាហរណ៍៖ ហិរញ្ញវត្ថុការរៀបចំស្ថាប័ន ) ក្រោយមកគម្រោងសាកល្បងត្រូវបាន ពង្រីកសកម្មភាពទៅ កាន់ខេត្តនានា និង/ ឬគម្រោងផ្តល់នូវសេវា និងការគាំទ្រជាច្រើន យ៉ាងទូលំទូលាយ។ ការសម្រេចទៅបានទាំងនេះ គឺវាអាចកើត ឡើងចំពោះគម្រោង ដែលបានជ្រើសរើសមួយចំនួនតែប៉ុណ្ណោះ។

ពីការអនុវត្តឈានទៅការបង្កើតគោលនយោបាយ៖ យោងតាម លទ្ធផលនៃការវាយតម្លៃ និងការចងក្រងឯកសារដូចបានរៀបរាប់ ខាងលើ គឺបានផ្តល់ព័ត៌មានពីកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ចូល វិធីសាស្ត្រ ASP ទៅក្នុងក្របខ័ណ្ឌគោលនយោបាយរបស់រាជ រដ្ឋាភិបាលកម្ពុជា ដែលនឹងមានបង្ហាញនៅក្នុងផែនការយុទ្ធ សាស្ត្រអភិវឌ្ឍន៍ជាតិ 5 ឆ្នាំបន្ទាប់ ( 2018-2022 ) ក៏ដូចជាយុទ្ធ សាស្ត្រវិស័យពាក់ព័ន្ធ មានដូចជា NSPS។ ដើម្បីអាចសម្រេច បាននូវការដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌគោលនយោបាយជាតិ ទាំងនេះយើងត្រូវគិតដោយប្រុងប្រយ័ត្នទាក់ទងទៅនឹងមធ្យោបាយ និងពេលវេលាណាដែលសមស្របក្នុងការគៀងគរ ការចូលរួម ពីក្រសួងផែនការ ( MoP ) និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ( MEF )។

ការធ្វើផែនការសម្រាប់រយៈពេលប្រាំឆ្នាំលើកទីពីរ៖ ការធ្វើផែនការ សម្រាប់រយៈពេលប្រាំឆ្នាំ លើកទីពីរ គួរចាប់ផ្តើមនៅចុង បញ្ចប់នៃដំណាក់កាលទីបី។ ក្នុងអំឡុងដំណាក់កាលទី 4 ផែនការ សកម្មភាពសម្រាប់រយៈពេលប្រាំឆ្នាំលើកទីពីរនឹងត្រូវបានបង្កើត កាន់តែរឹងមាំថែមទៀត ដើម្បីជួយគៀងគរធនធានហិរញ្ញវត្ថុ។ វា ត្រូវបានគេរំពឹងថា និរន្តរភាពនៃគំរោងគឺអាស្រ័យលើការបង្កើន បន្តិចម្តងៗលើការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុសម្រាប់ ASP ដោយរាជរដ្ឋាភិបាលកម្ពុជា។ ការនេះនឹងតម្រូវឱ្យមានកិច្ចពិភាក្សា ស្មោះត្រង់រវាងរាជរដ្ឋាភិបាលកម្ពុជា ដៃគូបច្ចេកទេស និងដៃគូ ហិរញ្ញវត្ថុ ដើម្បីបញ្ជាក់ពីការរំពឹងទុកទៅវិញទៅមក។ ជាការពិត ណាស់ ការពិភាក្សាបែបនេះគួរតែចាប់ផ្តើមឱ្យបានលឿន និងប្រែ ក្លាយជាផ្នែកមួយនៃដំណើរការបន្ត។ នេះគូសបញ្ជាក់អំពី សារៈសំខាន់នៃការចូលរួមពីតួអង្គរាជរដ្ឋាភិបាល ទូលំទូលាយ នៅក្នុងដំណើរការដំបូង រួមមានដូចជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្រសួងផែនការ និងក្រសួងមហាផ្ទៃ ( NCDD )។



Flooded School, Siem Reap (Photo - Humanitarian Response Forum 2013)

# ៥. ឯកសារពិគ្រោះ

Béné and Tech (2014) Adaptive Social Protection in Cambodia – situation Analysis. Report to the UNDP Cambodia Office, Institute of Development Studies, University of Sussex, Brighton, 33 p.

Manda and Yamamoto (2014) Cambodian Adaptive Social Protection Theory of Change Workshops Report UNDP APRC, 17 p.

Davies, M.; Leavy, J.; Mitchell, T. and Tanner, T. (2008) Social Protection and Climate Change, Briefing Note for Expert Group to the Commission on Climate Change and Development, Ministry of Foreign Affairs, Sweden.

Davies, M.; Guenther, B.; Leavy, J.; Mitchell, T. and Tanner, T. (2009) Climate Change Adaptation, Disaster Risk Reduction and Social Protection: Complementary Roles in Agriculture and Rural Growth? Working Paper 320, Brighton: Institute of Development Studies

Davies, M., Béné C. Arnall, A., Tanner T., Newsham A., Coirolo C., (2013) Promoting resilient livelihoods through Adaptive Social Protection: lessons from 124 programmes in South Asia Development Policy Review, 31(1): 27-58

ILO (2012) Cambodia: financial assessment of the national social protection strategy for the poor and vulnerable/ EU/ILO Project on Improving Social Protection and Promoting Employment; International Labour Office. - Geneva: ILO.

Royal Government of Cambodia (RGC). 2011. National Social Protection Strategy for the Poor and Vulnerable, prepared by the Council for Agricultural and Rural Development (CARD) Phnom Penh.

*Empowered lives.*
*Resilient nations.*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

អគារលេខ ៥៣ វិថី ប៉ាស្ទ័រ សង្កាត់ បឹងកេងកង
ប្រអប់សំបុត្រលេខ ៨៧៧ ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ +855 (0) 23 216 167
ទូរសារ ៖ +855 (0) 23 216 257
អ៊ីម៉ែល ៖ registry.kh@undp.org

www.kh.undp.org
www.facebook.com/UNDPCambodia
www.twitter.com/UNDPCambodia